# ព្រះរាជក្រម

នស/រកម/០៣១៥/០០៣

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

ចូល លេខ ថ្ងៃទី ឆ្នាំ២០១ ម៉ោង បញ្ជូនទៅ

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ១៩៩៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១០៧/០០៥ ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

## ប្រកាសឲ្យប្រើ

ច្បាប់ ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី១៩ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៥ ហើយដែលព្រឹទ្ធសភាបានពិនិត្យចប់សព្វគ្រប់លើទម្រង់ និងគតិច្បាប់នេះទាំងស្រុងកាលពីថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៥ នាសម័យប្រជុំលើកទី៦ នីតិកាលទី៣ ព្រមទាំងត្រូវបានក្រុមប្រឹក្សាធម្មនុញ្ញប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ក្នុងសេចក្តីសម្រេចលេខ ១៥៤/០០២/២០១៥ កបធ.ប ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅ ៖

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL
រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង

# ច្បាប់

# ស្តីពី

# ការបោះឆ្នោតជ្រើសតាំង

# តំណាងរាស្ត្រ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

### មាត្រា ១.-

ច្បាប់នេះមានគោលដៅកំណត់បែបបទ និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ដែលជាសមាជិករដ្ឋសភានៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ២.-

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវអនុវត្តតាមគោលការណ៍នៃលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ។

### មាត្រា ៣.-

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើឡើងរៀងរាល់ ០៥ (ប្រាំ) ឆ្នាំម្តង ។

កាលបរិច្ឆេទនៃការបោះឆ្នោត ត្រូវកំណត់ និងប្រកាសដោយនាយករដ្ឋមន្ត្រី តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ។

ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវធ្វើនៅថ្ងៃអាទិត្យតែ ០១ (មួយ) ថ្ងៃ លើកលែងតែក្នុងស្ថានភាពណាមួយដូចខាងក្រោម ៖

-ក្នុងករណីប្រធានសក្តិដែលចាំបាច់ត្រូវលើកថ្ងៃបោះឆ្នោត ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ។ ក្នុងករណីនេះការបោះឆ្នោតជ្រើសតាំងរដ្ឋសភាថ្មី ត្រូវប្រព្រឹត្តទៅក្នុងរយៈពេល ៦០ (ហុកសិប)ថ្ងៃយ៉ាងយូរ ចាប់ពីថ្ងៃរំលាយរដ្ឋសភា ។

-ក្នុងករណីដែលរដ្ឋសភាត្រូវបានប្រកាសឲ្យបន្តនីតិកាលរបស់ខ្លួន ស្របតាមកថាខណ្ឌទី ៥ នៃមាត្រា ៧៨ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

### មាត្រា ៤.-

ការគ្រប់គ្រងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ជាសមត្ថកិច្ចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដូចមានចែងក្នុងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

# ជំពូកទី ២
# ប្រព័ន្ធបោះឆ្នោត និងការកំណត់អាសនៈ

## មាត្រា ៥.-

តំណាងរាស្ត្រត្រូវបានជ្រើសតាំងដោយការបោះឆ្នោតជាទូទៅ ជាសកល ដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ដោយស្មើភាព ដោយចំពោះ តាមវិធីជ្រើសរើសឆ្នោតជាសម្ងាត់ ។

ការបោះឆ្នោតត្រូវធ្វើតាមប្រព័ន្ធសមាមាត្រតាមរាជធានី ខេត្ត ដោយយករាជធានី ខេត្តជាមណ្ឌលបោះឆ្នោត ។

## មាត្រា ៦.-

អាសនៈនៅក្នុងរដ្ឋសភាមានចំនួន ១២៥ (មួយរយម្ភៃប្រាំ) ដែលបែងចែកតាមមណ្ឌលរាជធានី ខេត្ត ដូចខាងក្រោម ៖

| | |
|---|---|
| -មណ្ឌលខេត្តបន្ទាយមានជ័យ | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តបាត់ដំបង | ចំនួន ០៨ (ប្រាំបី) អាសនៈ |
| -មណ្ឌលខេត្តកំពង់ចាម | ចំនួន ១០ (ដប់) អាសនៈ |
| -មណ្ឌលខេត្តត្បូងឃ្មុំ | ចំនួន ០៨ (ប្រាំបី) អាសនៈ |
| -មណ្ឌលខេត្តកំពង់ឆ្នាំង | ចំនួន ០៤ (បួន) អាសនៈ |
| -មណ្ឌលខេត្តកំពង់ស្ពឺ | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តកំពង់ធំ | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តកំពត | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តកណ្ដាល | ចំនួន ១១ (ដប់មួយ) អាសនៈ |
| -មណ្ឌលខេត្តកោះកុង | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលខេត្តក្រចេះ | ចំនួន ០៣ (បី) អាសនៈ |
| -មណ្ឌលខេត្តមណ្ឌលគិរី | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលរាជធានីភ្នំពេញ | ចំនួន ១២ (ដប់ពីរ) អាសនៈ |
| -មណ្ឌលខេត្តព្រះវិហារ | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលខេត្តព្រៃវែង | ចំនួន ១១ (ដប់មួយ) អាសនៈ |
| -មណ្ឌលខេត្តពោធិ៍សាត់ | ចំនួន ០៤ (បួន) អាសនៈ |
| -មណ្ឌលខេត្តរតនគិរី | ចំនួន ០១ (មួយ) អាសនៈ |

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

| | |
|---|---|
| -មណ្ឌលខេត្តសៀមរាប | ចំនួន ០៦ (ប្រាំមួយ) អាសនៈ |
| -មណ្ឌលខេត្តព្រះសីហនុ | ចំនួន ០៣ (បី) អាសនៈ |
| -មណ្ឌលខេត្តស្ទឹងត្រែង | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលខេត្តស្វាយរៀង | ចំនួន ០៥ (ប្រាំ) អាសនៈ |
| -មណ្ឌលខេត្តតាកែវ | ចំនួន ០៨ (ប្រាំបី) អាសនៈ |
| -មណ្ឌលខេត្តកែប | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលខេត្តប៉ៃលិន | ចំនួន ០១ (មួយ) អាសនៈ |
| -មណ្ឌលខេត្តឧត្តរមានជ័យ | ចំនួន ០១ (មួយ) អាសនៈ ។ |

## ជំពូកទី ៣
## ភ្នាក់ងារគណបក្សនយោបាយ
## និងអ្នកសង្កេតការណ៍បោះឆ្នោត

### មាត្រា ៧.-

គណបក្សនយោបាយនីមួយៗដែលឈរឈ្មោះបោះឆ្នោត មានសិទ្ធិចាត់តាំងតំណាងរបស់ខ្លួន ០២ (ពីរ) រូប ពេញសិទ្ធិ ០១ (មួយ) រូប និងបម្រុង០១ (មួយ) រូប ក្នុងចំណោមអ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ហៅថាភ្នាក់ងារគណបក្សនយោបាយ ដើម្បីចូលរួមសង្កេតការណ៍មើលការបោះ-ឆ្នោត តាមការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតនីមួយៗ ។

ភ្នាក់ងារពេញសិទ្ធិត្រូវបានអនុញ្ញាតឲ្យចូលក្នុងការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោត។

ភ្នាក់ងារបម្រុងត្រូវបានអនុញ្ញាតឲ្យជំនួសភ្នាក់ងារពេញសិទ្ធិ ក្នុងករណីដែលភ្នាក់ងារពេញសិទ្ធិអវត្តមាន។

គណបក្សនយោបាយនីមួយៗ មានសិទ្ធិផ្លាស់ប្តូរភ្នាក់ងារគណបក្សនយោបាយរបស់ខ្លួន ។

### មាត្រា ៨.-

គណបក្សនយោបាយដែលមានបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនមកគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទនៃការបិទផ្សាយបញ្ជីបេក្ខជនតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣៧ នៃច្បាប់នេះ ។

ពាក្យសុំចុះឈ្មោះជាភ្នាក់ងារគណបក្សនយោបាយ ត្រូវបញ្ជាក់នាមត្រកូល នាមខ្លួន ថ្ងៃខែឆ្នាំកំណើត អាសយដ្ឋាន និងលិខិតបញ្ជាក់ការចុះឈ្មោះបោះឆ្នោត នៅការិយាល័យបោះឆ្នោតណាមួយក្នុងឃុំ សង្កាត់ និងការិយាល័យបោះឆ្នោតដែលភ្នាក់ងារនោះត្រូវបំពេញការងារ ។

**មាត្រា ៩.-**

គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ ហើយផ្តល់ប័ណ្ណសម្គាល់ដល់ភ្នាក់-ងារគណបក្សនយោបាយណាដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ ។

ក្នុងករណីភ្នាក់ងារពេញសិទ្ធិ និងភ្នាក់បម្រុងណាម្នាក់ដែលបំពេញមិនបានត្រឹមត្រូវតាមលក្ខ-ខណ្ឌ ដូចមានចែងក្នុងមាត្រា ៧ និងមាត្រា ៨ នៃច្បាប់នេះ គណៈកម្មការឃុំ សង្កាត់រៀបចំការបោះ-ឆ្នោត ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅគណបក្សនយោបាយសាមី ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ ក្រោយពីបានទទួលពាក្យស្នើសុំ ។

គណបក្សនយោបាយ មានសិទ្ធិដាក់ពាក្យស្នើសុំចុះឈ្មោះភ្នាក់ងារពេញសិទ្ធិ និងភ្នាក់ងារបម្រុងរបស់ខ្លួនជាថ្មីមួយលើកទៀត ជំនួសឈ្មោះភ្នាក់ងារពេញសិទ្ធិ និង ភ្នាក់ងារបម្រុងដែលបានបដិសេធមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

**មាត្រា ១០.-**

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល អាចបញ្ជូនតំណាងរបស់ខ្លួនឲ្យមកចូលរួមជាអ្នកសង្កេតការណ៍បោះឆ្នោត ។

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ត្រូវរៀបចំសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតទៅតាមពេលវេលាបែបបទ និងនីតិវិធី ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចុះឈ្មោះ និងផ្តល់ប័ណ្ណសម្គាល់ឲ្យអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលណា ដែលមានលក្ខណសម្បត្តិត្រឹមត្រូវតាមការកំណត់ ដូចមានចែងក្នុងបទបញ្ជា និងនីតិវិធីរបស់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

## មាត្រា ១២.-

ក្នុងករណីអ្នកសង្កេតការណ៍ណាម្នាក់ ដែលគ្មានលក្ខណសម្បត្តិគ្រប់គ្រាន់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបដិសេធឈ្មោះរបស់ជននោះជាលាយលក្ខណ៍អក្សរទៅសាមីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលបានដាក់ពាក្យសុំសង្កេតការណ៍បោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលពាក្យស្នើសុំ ។

## មាត្រា ១៣.-

សមាគម និងអង្គការមិនមែនរដ្ឋាភិបាល មានសិទ្ធិដាក់ពាក្យសុំចុះឈ្មោះជាអ្នកសង្កេតការណ៍នៃសមាគម និងអង្គការមិនមែនរដ្ឋាភិបាលជាថ្មីមួយលើកទៀត ជំនួសឈ្មោះអ្នកសង្កេតការណ៍ដែលបានបដិសេធ ឲ្យមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតក្នុងរយៈពេលយ៉ាងយូរ ០៣ (បី) ថ្ងៃ បន្ទាប់ពីបានទទួលលិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរអំពីការបដិសេធ ។

## មាត្រា ១៤.-

ភ្នាក់ងារគណបក្សនយោបាយនីមួយៗដែលទទួលបានការអនុញ្ញាត មានសិទ្ធិ មានវត្តមាននៅតាមការិយាល័យបោះឆ្នោត ឬការិយាល័យរាប់សន្លឹកឆ្នោត តាមបទបញ្ជា និងនីតិវិធីរបស់គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ១៥.-

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមានសិទ្ធិជំទាស់ ឬតវ៉ា រាល់ការរំលោភទៅលើច្បាប់នេះ ឬលើបទបញ្ជា និងនីតិវិធីនៃការបោះឆ្នោតដែលភ្នាក់ងារនោះបានឃើញផ្ទាល់ ។

## មាត្រា ១៦.-

ការជំទាស់ ឬការតវ៉ា ដូចមានចែងក្នុងមាត្រា ១៥ នៃច្បាប់នេះ ត្រូវធ្វើឡើងទៅប្រធានគណៈ-កម្មការការិយាល័យបោះឆ្នោត ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោត នៅពេលមានការរំលោភ ឬបន្ទាប់ពីមានការរំលោភ។

## មាត្រា ១៧.-

របៀបបែបបទនៃការជំទាស់ ឬការតវ៉ា ដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា ១៦ នៃច្បាប់នេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ១៨.-

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត ភ្នាក់ងារគណបក្សនយោបាយមិនត្រូវ ៖

-ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត ។

-រំខាន ឬជ្រៀតជ្រែកដំណើរការបោះឆ្នោត និងដំណើរការរាប់សន្លឹកឆ្នោត ។

-លើកឡើងនូវការជំទាស់ ឬការតវ៉ាទៅជនណាម្នាក់ក្រៅពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ឬប្រធានការិយាល័យរាប់សន្លឹកឆ្នោតបានឡើយ ។

-រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ១៩.-

ក្នុងការសង្កេតមើលដំណើរការបោះឆ្នោត និងការរាប់សន្លឹកឆ្នោត អ្នកសង្កេតការណ៍មិនត្រូវ ៖

-ផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះឆ្នោត និងមន្ត្រីរាប់សន្លឹកឆ្នោត ។

-រំខាន ឬជ្រៀតជ្រែកដំណើរការបោះឆ្នោត និងដំណើរការរាប់សន្លឹកឆ្នោត ។

-រំលោភទៅលើបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

### មាត្រា ២០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការផ្សព្វផ្សាយដល់គណបក្សនយោបាយ សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដែលទទួលសង្កេតការណ៍បោះឆ្នោត អំពីការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ បទប្បញ្ញត្តិសំខាន់ៗនៃច្បាប់នេះ ព្រមទាំងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

### មាត្រា ២១.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវអញ្ជើញតំណាងអង្គការក្រៅរដ្ឋាភិបាលបរទេស តំណាងប្រទេសនានា និងតំណាងអង្គការអន្តរជាតិ ឲ្យចូលរួមសង្កេតការណ៍ ការបោះឆ្នោត ។

### មាត្រា ២២.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចតាក់តែងបទបញ្ជាសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នានា អនុលោមទៅតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

## ជំពូកទី ៤
## ការចុះបញ្ជីគណបក្សនយោបាយ
## ឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

### មាត្រា ២៣.–

ប្រជាពលរដ្ឋខ្មែរដែលមានសិទ្ធិ និងមានបំណងឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម ៖

១-មានសញ្ជាតិខ្មែរពីកំណើត

២-មានអាយុ ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

៣-មានសិទ្ធិបោះឆ្នោត និងមានឈ្មោះក្នុងបញ្ជីបោះឆ្នោត

៤-មានលំនៅឋាន ឬទីសំណាក់ក្នុងព្រះរាជាណាចក្រកម្ពុជា

៥-មានការតែងតាំងពីគណបក្សនយោបាយ ដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត ។

### មាត្រា ២៤.–

គ្មានសិទ្ធិឈរឈ្មោះជាបេក្ខជនបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ៖

១-មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ ក្នុងមុខតំណែង និងបព្វជិតសាសនា ឬ

២-ជនដែលត្រូវបានតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ហើយដែលមិនទាន់មាននីតិសម្បទាឡើងវិញ ឬ

៣-ជនដែលត្រូវផ្តន្ទាទោសដកសិទ្ធិបោះឆ្នោតឬដកសិទ្ធិឈរឈ្មោះឲ្យគេបោះឆ្នោត

៤-ជនវិកលចរិត ឬជនដែលស្ថិតនៅក្រោមអាណាព្យាបាលទូទៅដែលមានលិខិតបញ្ជាក់ពីក្រសួងមានសមត្ថកិច្ច ឬ

៥-ជនដែលត្រូវដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ឬជនដែលត្រូវបានលុបឈ្មោះពីបញ្ជីឈ្មោះបោះឆ្នោត ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬ

៦-សមាជិកនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ឬ

៧-សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ឬ

៨-សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

**មាត្រា ២៥.-**

មន្ត្រីរាជការស៊ីវិល មន្ត្រីតុលាការ កងកម្លាំងនគរបាលជាតិ កងយោធពលខេមរភូមិន្ទ សមាជិកក្រុមប្រឹក្សាធម្មនុញ្ញ សមាជិកឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងបព្វជិតសាសនាដែលមានបំណងឈរឈ្មោះបោះឆ្នោតជ្រើសតាំងជាតំណាងរាស្ត្រ ត្រូវដាក់ពាក្យសុំច្បាប់ឈប់ពិសេស ឬលាចាកសិក្ខាបទរហូតដល់ថ្ងៃប្រកាសលទ្ធផលនៃការបោះឆ្នោតជាស្ថាពរយ៉ាងតិច ០៧ (ប្រាំពីរ)ថ្ងៃ មុនថ្ងៃបើកយុទ្ធនាការឃោសនាបោះឆ្នោត ។

ប្រសិនបើសាមីខ្លួនជាប់ឆ្នោត សាមីខ្លួនត្រូវដាក់ពាក្យសុំតាមឋានានុក្រមទៅសាមីក្រសួង ឬសាមីអង្គភាព ទៅបម្រើការក្រៅក្របខ័ណ្ឌដើម ក្នុងរយៈពេលអាណត្តិរបស់ខ្លួន ។ ក្នុងរយៈពេលស្ថិតនៅក្រៅក្របខ័ណ្ឌដើម សាមីខ្លួនត្រូវមានសិទ្ធិឡើងឋានន្តរសក្តិ និងឡើងថ្នាក់ដោយស្វ័យប្រវត្តិ និងរក្សាអតីតភាពការងារសម្រាប់ទទួលសោធននិវត្តន៍ ។

នៅពេលចប់អាណត្តិជាតំណាងរាស្ត្រ សាមីខ្លួនអាចសុំត្រឡប់មកបម្រើការនៅក្រសួង ឬអង្គភាពដើមវិញ ប៉ុន្តែមុខងារអាស្រ័យដោយសាមីក្រសួង ឬសាមីអង្គភាពជាអ្នកសម្រេច ។

**មាត្រា ២៦.-**

បែបបទនៃការអនុវត្តមាត្រា២៣ និងមាត្រា២៤ នៃច្បាប់នេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ២៧.-**

ការបើកបញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវចាប់ផ្តើម ៩០ (កៅសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

ដើម្បីចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រជាផ្លូវការ គណបក្សនយោបាយត្រូវធ្វើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត តាមបែបបទកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត មកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយ៉ាងយូរ ៧០ (ចិតសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោតដោយភ្ជាប់មកជាមួយ ៖

១-សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយ នៅក្រសួងមហាផ្ទៃ ០១ (មួយ) ច្បាប់ ។

២-ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់និងសញ្ញាសម្គាល់គណបក្សនយោបាយ ។

៣-អាសយដ្ឋាននៃទីស្នាក់ការកណ្តាលរបស់គណបក្សនយោបាយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

៤-បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបទូទាំងប្រទេស ។ បញ្ជីនេះត្រូវមានបេក្ខជនពេញសិទ្ធិចំនួនយ៉ាងតិច ១/៣ (មួយភាគបី) នៃចំនួនអាសនៈក្នុងរដ្ឋសភា និងបេក្ខជនបម្រុងចំនួនស្មើគ្នានឹងបេក្ខជនពេញសិទ្ធិ ។

៥-ឈ្មោះមណ្ឌលដែលគណបក្សនយោបាយមានបំណងទៅឈរ និងបញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលទាំងនោះ ។ បញ្ជីបេក្ខជនឈរឈ្មោះតាមមណ្ឌលត្រូវមានចំនួនបេក្ខជនគ្រប់តាមចំនួនកំណត់អាសនៈ និងតាមគំរូដែលគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតផ្តល់ឲ្យ ។

ចំពោះមណ្ឌលបោះឆ្នោតដែលមានអាសនៈ ០១ (មួយ) ឬ ០២ (ពីរ) ត្រូវមានបេក្ខជនបម្រុងចំនួនយ៉ាងតិច ០៣ (បី) រូប ។

៦-សេចក្តីប្រកាសអំពីគណនីធនាគារ ដែលគណបក្សនយោបាយបានទុកប្រាក់ចំណូលផ្សេងៗរួមមានទាំងវិភាគទានដែលបានមកពីប្រភពណាក៏ដោយ នៅធនាគារក្នុងព្រះរាជាណាចក្រកម្ពុជាដែលមានការទទួលស្គាល់ពីធនាគារជាតិនៃកម្ពុជា ។

៧-លក្ខន្តិកៈគណបក្សនយោបាយ និងឯកសារផ្សេងៗដែលបញ្ជាក់ពីការបង្កើតគណបក្សនយោបាយ ។

៨-សេចក្តីប្រកាសរបស់គណបក្សនយោបាយសន្យាថា ចូលរួមបោះឆ្នោត និងទទួលយកលទ្ធផលនៃការបោះឆ្នោតដែលប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ និងចូលរួមអនុវត្តច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ក្រមសីលធម៌ និងច្បាប់ស្តីពីគណបក្សនយោបាយ ។

៩-បញ្ជីរាយនាមគណៈកម្មាធិការនាយក ឬគណៈកម្មាធិការអចិន្ត្រៃយ៍ ឬអង្គការសមមូលរបស់គណបក្សនយោបាយ ។

១០-បង្កាន់ដៃបង់ប្រាក់តម្កល់ចំនួន ១៥.០០០.០០០ (ដប់ប្រាំលាន) រៀល ដែលចេញដោយរតនាគារជាតិ ។ ប្រាក់តម្កល់នេះត្រូវបានបង្វិលជូនទៅសាមីគណបក្សនយោបាយវិញ ក្នុងករណីដែលគណបក្សនយោបាយនោះ បានទទួលសន្លឹកឆ្នោតយ៉ាងតិច ០៣ (បី) ភាគរយ នៃចំនួនសន្លឹកឆ្នោតបានការ ឬបានអាសនៈ ០១ (មួយ) ក្នុងរដ្ឋសភា ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ការចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវប្រព្រឹត្តទៅរយៈពេល ១០ (ដប់) ថ្ងៃ គិតពីថ្ងៃប្រកាសរំលាយរដ្ឋសភា ។

**មាត្រា ២៨.-**

បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមមណ្ឌលត្រូវ ៖

១-ចុះឈ្មោះតាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមការកំណត់របស់គណបក្សនយោបាយ

ROYAUME DU CAMBODGE LE MINISTERE DU PALAIS ROYAL

២-មានសេចក្តីបញ្ជាក់អំពីការចុះឈ្មោះបោះឆ្នោត ដោយអាជ្ញាធរឃុំ សង្កាត់ដែលសាមីខ្លួនបេក្ខជននោះ បានចុះឈ្មោះបោះឆ្នោត

៣-ភ្ជាប់សេចក្តីប្រកាសរបស់បេក្ខជនយល់ព្រមទទួលការតែងតាំងជាបេក្ខជន តាមមណ្ឌលរបស់គណបក្សនយោបាយ ។

**មាត្រា ២៩.-**

បេក្ខជនម្នាក់ៗត្រូវមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់មណ្ឌលតែមួយគត់ ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនឈរឈ្មោះលើសពីមួយមណ្ឌល ត្រូវបានប្រកាសថាបាត់សិទ្ធិឈរឈ្មោះជាបេក្ខជនដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ទោះជាសាមីខ្លួនទៅឈរឈ្មោះជាបេក្ខជនឈរឈ្មោះក្នុងគណបក្សនយោបាយណាផ្សេងទៀតក៏ដោយ ។

**មាត្រា ៣០.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវកំណត់កាលបរិច្ឆេទនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្សព្វផ្សាយជាសាធារណៈនូវកាលបរិច្ឆេទ ទីកន្លែង និងរយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ។

ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ គឺរៀងរាល់ថ្ងៃ ពេលព្រឹកចាប់ពីម៉ោង ៧:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:៣០នាទី ។

ក្នុងករណីរដ្ឋសភាត្រូវបានរំលាយមុនអាណត្តិ រយៈពេលនៃការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ត្រូវកំណត់ផ្សេងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបង្កាន់ដៃនៃការទទួលពាក្យដែលមានចុះហត្ថលេខា ឬស្នាមមេដៃនៃអ្នកទទួល និងអ្នកប្រគល់ជូនគណបក្សនយោបាយ ដែលបានដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងរក្សាគល់បញ្ជី ០១ (មួយ) ច្បាប់ទុកជាឯកសារ ។

**មាត្រា ៣១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវពិនិត្យលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ)ថ្ងៃ បន្ទាប់ពីបានទទួលពាក្យសុំ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ត្រូវពិនិត្យ និងសម្រេចលើពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជាបន្ទាន់ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជូនសាមីគណបក្សនយោបាយ ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពិនិត្យឃើញថា សំណុំលិខិតរបស់គណបក្សនយោបាយនោះពុំបានបំពេញលក្ខខណ្ឌណាមួយ ដែលមានចែងក្នុងមាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៧ និងមាត្រា ២៨ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវជូនដំណឹងទៅសាមីគណបក្សនយោបាយវិញ ដើម្បីបំពេញបន្ថែម ។

គណបក្សនយោបាយនេះត្រូវបំពេញលក្ខខណ្ឌដែលខ្វះខាតយ៉ាងយូរ ០៥(ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃដែលសាមីគណបក្សនយោបាយបានទទួលលិខិតជូនដំណឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិគណបក្សនយោបាយត្រូវបំពេញលក្ខ-ខណ្ឌ ដែលខ្វះខាតឲ្យបានទាន់មុនពេលបញ្ចប់បញ្ជីចុះឈ្មោះគណបក្សនយោបាយឈរឈ្មោះបោះ-ឆ្នោត ។

ផុតកំណត់នេះ បើគណបក្សនយោបាយពុំបានបំពេញលក្ខខណ្ឌទាំងនោះទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចាត់ទុកថា គណបក្សនយោបាយនោះបោះបង់ការចុះបញ្ជីគណបក្សនយោ-បាយឈរឈ្មោះបោះឆ្នោត ។

**មាត្រា ៣២.-**

ប្រសិនបើបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនណាមួយត្រូវបានបដិសេធតាមបទប្បញ្ញត្តិនៃមាត្រា ២៣ ឬមាត្រា ២៤ ឬមាត្រា ២៥ ឬមាត្រា ២៨ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-បំពេញបែបបទនៃការបដិសេធបេក្ខភាព ឬបញ្ជីរាយនាមបេក្ខជនដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ទៅសាមីខ្លួន និងសាមីគណបក្សនយោបាយ ។

-ផ្តល់ព័ត៌មានដល់សាមីខ្លួន និងទៅសាមីគណបក្សនយោបាយថា អនុលោមតាមមាត្រា ៣៣ នៃច្បាប់នេះ សាមីខ្លួន ឬសាមីគណបក្សនយោបាយអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួន ឬសាមីគណបក្សនយោបាយ អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

-ផ្ញើសេចក្ដីចម្លងនៃសេចក្ដីបដិសេធ ០១ (មួយ) ច្បាប់ជូនក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ជាឯកសារ ។

**មាត្រា ៣៣.-**

បេក្ខភាពណាដែលត្រូវបានបដិសេធ ឬបញ្ជីរាយនាមបេក្ខជនរបស់គណបក្សនយោបាយណា ដែលត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សាមីខ្លួន ឬសាមីគណបក្សនយោបាយនោះ មានសិទ្ធិប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលលិខិតជូនដំណឹងបដិសេធ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ សាមីខ្លួន ឬសាមីគណបក្សនយោបាយ អាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញជាបន្ទាន់ ។

ក្នុងករណីបានទទួលសម្រង់នៃសេចក្ដីសម្រេចបដិសេធ និងទម្រង់បែបបទសម្រាប់ប្ដឹងតវ៉ា ហើយ ប៉ុន្តែ សាមីគណបក្សនយោបាយឬតំណាងពុំបានដាក់ពាក្យប្ដឹងតវ៉ាទៅតាមពេលវេលាកំណត់ ដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ ខាងលើនេះទេ ត្រូវចាត់ទុកថា គណបក្សនយោបាយនោះ មិនបានប្ដឹងតវ៉ា ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ានេះ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃ យ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្ដឹង ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនផុតអាណត្តិ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវពិនិត្យ និងសម្រេចលើបណ្ដឹងតវ៉ានេះជាបន្ទាន់ ។

**មាត្រា ៣៤.-**

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមលើបណ្ដឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវចេញសេចក្ដីសម្រេចយល់ព្រម និងជូនដំណឹងទៅសាមីគណបក្សនយោបាយ ឬតំណាង ហើយបង្គាប់ឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះសាមីគណបក្សនយោបាយទៅក្នុងបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ជ្រើសតាំងតំណាងរាស្ត្រជាបន្ទាន់ ។

បន្ទាប់ពីទទួលសេចក្ដីសម្រេចពីក្រុមប្រឹក្សាធម្មនុញ្ញ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញលិខិតបញ្ជាក់អំពីការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជូនសាមីគណបក្សនយោបាយ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្ញើលិខិតនេះ ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៣៥.-**

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចបដិសេធបណ្តឹងតវ៉ា សេចក្តីសម្រេចនេះ គឺជាសេចក្តីសម្រេចចុងក្រោយ បិទផ្លូវតវ៉ា ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវផ្តល់សេចក្តីសម្រេចបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅសាមីគណបក្សនយោបាយ ឬតំណាង និងផ្ញើសេចក្តីសម្រេចបដិសេធ ០១ (មួយ) ច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៣៦.-**

សវនាការឬផ្នែកមួយនៃសវនាការរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ដែលវិនិច្ឆ័យទៅលើបណ្តឹងតវ៉ា ត្រូវធ្វើជាចំហ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបិទផ្សាយ ថ្ងៃ ខែ ឆ្នាំ ទីកន្លែង និងពេលវេលានៃការបើកសវនាការវិនិច្ឆ័យលើបណ្តឹងតវ៉ានេះ ។

**មាត្រា ៣៧.-**

បន្ទាប់ពីបានបញ្ឈប់ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត ឬ/និងក្រោយពេលដែលបណ្តឹងតវ៉ាត្រូវបានដោះស្រាយជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបិទផ្សាយបញ្ជីរាយនាមគណបក្សនយោបាយទាំងអស់ដែលបានចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតតាមរាជធានី ខេត្តរបស់គណបក្សនយោបាយទាំងនោះ ទៅតាមការកំណត់ ដូចមានចែងក្នុងបទបញ្ជា និងនីតិវិធី ។

## ជំពូកទី ៥
## ការិយាល័យបោះឆ្នោត

**មាត្រា ៣៨.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចបង្កើតការិយាល័យបោះឆ្នោតមួយ ឬច្រើនសម្រាប់ឃុំ សង្កាត់នីមួយៗ ស្របតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវទទួលខុសត្រូវតំបន់មួយដែលបានកំណត់ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ការិយាល័យបោះឆ្នោត និងតំបន់ដែលការិយាល័យនោះទទួលខុសត្រូវ ត្រូវស្ថិតនៅក្នុងព្រំប្រទល់ឃុំ សង្កាត់របស់ខ្លួន ។

**មាត្រា ៣៩.-**

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវមានប្រជាពលរដ្ឋដែលមានឈ្មោះបោះឆ្នោតយ៉ាងច្រើន ៧៥០ (ប្រាំពីររយហាសិប) នាក់ ។

ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវប្រមូលផ្តុំដោយភូមិទាំងមូល និងត្រូវបង្កលក្ខណៈឲ្យសមាជិកទាំងអស់របស់គ្រួសារក្នុងភូមិបានទៅបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ។

ក្នុងករណីដែលការិយាល័យបោះឆ្នោតណាមួយមានចំនួនអ្នកបោះឆ្នោតលើសពី ៧៥០ (ប្រាំពីររយហាសិប) នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ចូលឈ្មោះអ្នកដែលលើសនោះ ទៅក្នុងការិយាល័យបោះឆ្នោតដែលនៅជិតបំផុតក្នុងឃុំ សង្កាត់ជាមួយ ឬអាចបង្កើតការិយាល័យបោះឆ្នោតថ្មី តាមការចាំបាច់ ។

**មាត្រា ៤០.-**

គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ត្រូវមានបរិវេណខាងក្នុងដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្នុងជាតំបន់ដែលនៅជុំវិញការិយាល័យបោះឆ្នោត និងការិយាល័យរាប់សន្លឹកឆ្នោតខណ្ឌដោយវង្វែងមណ្ឌលមួយ ដែលមានកាំប្រវែងយ៉ាងតិច ១៥ (ដប់ប្រាំ) ម៉ែត្រ ។

បរិវេណខាងក្នុងត្រូវរៀបចំឲ្យមានច្រកចូលមួយ និងច្រកចេញមួយ ។

**មាត្រា ៤១.-**

គ្រប់ការិយាល័យបោះឆ្នោត និងគ្រប់ការិយាល័យរាប់សន្លឹកឆ្នោត ត្រូវមានបរិវេណខាងក្រៅដែលដៅសម្គាល់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បរិវេណខាងក្រៅជាតំបន់ដែលនៅជុំវិញការិយាល័យទាំងនោះ ខណ្ឌដោយវង្វែងមណ្ឌលមួយដែលមានកាំប្រវែង ១០០ (មួយរយ) ម៉ែត្រ ឬមានទម្រង់ផ្សេង ឬមានកាំតូចជាង ស្របទៅតាមស្ថានភាពជាក់ស្តែងនៃបរិវេណខាងក្រៅរបស់ការិយាល័យនីមួយៗនោះ ។

**មាត្រា ៤២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតមានសិទ្ធិជ្រើសយកបរិវេណ ឬអគារតែមួយធ្វើជាការិយាល័យបោះឆ្នោត សម្រាប់ការិយាល័យបោះឆ្នោតពីរ ឬច្រើន ប្រសិនបើមិនធ្វើឲ្យប៉ះពាល់ដល់ប្រក្រតីភាពនៃការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការបោះឆ្នោត ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ក្រសួងព្រះបរមរាជវាំង

ការិយាល័យបោះឆ្នោតជាច្រើនដែលតាំងនៅបរិវេណ ឬអគារតែមួយនោះ ត្រូវរៀបចំឲ្យស្ថិតនៅដាច់ដោយឡែកពីគ្នា ។

ការិយាល័យបោះឆ្នោតនីមួយៗដែលតាំងនៅបរិវេណ ឬអគារតែមួយនោះ ត្រូវគ្រប់គ្រងឲ្យដាច់ចេញពីគ្នា និងខុសពីការិយាល័យបោះឆ្នោតផ្សេងទៀត ទៅតាមបទបញ្ជា និងនីតិវិធីដែលបានកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៣.-**

ឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតដែលបានកំណត់ហើយ ត្រូវបិទផ្សាយជាសាធារណៈ ។

គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតអាចសុំតារាងឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនេះបាន ដោយបង់ថ្លៃ ។

តម្លៃនេះ ត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបញ្ជូនតារាងឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនៃមណ្ឌលនីមួយៗ ០១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

## ជំពូកទី ៦
## ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត

**មាត្រា ៤៤.-**

ការចុះឈ្មោះបោះឆ្នោត និងបញ្ជីបោះឆ្នោត ត្រូវធានាសិទ្ធិបោះឆ្នោតរបស់ប្រជាពលរដ្ឋខ្មែរគ្រប់រូប ដែលបានបំពេញតាមលក្ខខណ្ឌនៃច្បាប់នេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យមានបញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ដែលបង្កើតឡើងតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ ។

បញ្ជីបោះឆ្នោតត្រូវកត់ត្រាទិន្នន័យអ្នកបោះឆ្នោតម្នាក់ៗ ដូចខាងក្រោម ៖

-នាមត្រកូល នាមខ្លួន

-ភេទ

-ថ្ងៃខែឆ្នាំកំណើត

-លំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ដែលសាមីខ្លួនត្រូវបោះឆ្នោត និង

-ការដៅសម្គាល់អត្តសញ្ញាណដែលមានតែមួយគត់សម្រាប់អ្នកបោះឆ្នោតម្នាក់ៗ ដូចជា រូបថត និងស្នាមម្រាមដៃ ឬ/និងការដៅសម្គាល់ផ្សេងទៀត តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

នាមត្រកូល នាមខ្លួន ភេទ និងថ្ងៃខែឆ្នាំកំណើតរបស់អ្នកបោះឆ្នោតម្នាក់ៗ ត្រូវស្រង់ចេញពីអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់អ្នកបោះឆ្នោតនោះ ។

បញ្ជីបោះឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ ត្រូវកត់ចូលក្នុងសៀវភៅបញ្ជីមួយ ឬប្រព័ន្ធទិន្នន័យ ហើយរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ នៅលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត និងនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្តល់សុពលភាព និងប្រកាសឲ្យបញ្ជីឈ្មោះបោះឆ្នោតផ្លូវការ ៩០ (កៅសិប) ថ្ងៃយ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយមុនអាណត្តិ បញ្ជីបោះឆ្នោតត្រូវយកបញ្ជីបោះឆ្នោតដែលមានសុពលភាពចុងក្រោយទុកជាផ្លូវការ ហើយត្រូវផ្សព្វផ្សាយបញ្ជីនេះយ៉ាងតិច ៥០ (ហាសិប) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៤៥.-**

សៀវភៅបញ្ជី ឬទិន្នន័យបញ្ជីបោះឆ្នោត ត្រូវរក្សាទុកជាអចិន្ត្រៃយ៍នៅសាលាឃុំ សង្កាត់ នៅលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត និងនៅទីស្នាក់ការគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ស្របតាមបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ។

រយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោត ត្រូវធ្វើចាប់ពីថ្ងៃទី ០១ ខែ ឧសភា ហូតដល់ថ្ងៃទី ៣១ ខែ កក្កដា ជារៀងរាល់ឆ្នាំ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចកាលបរិច្ឆេទ និងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះបោះឆ្នោត និងការចុះឈ្មោះបោះឆ្នោត និងផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតផ្សេងពីនេះ ។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចបន្ថែមរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតយ៉ាងយូរ៥០ (ហាសិប) ថ្ងៃ ។

ក្នុងករណីដែលរដ្ឋសភាត្រូវបានរំលាយក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ឬប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចសម្រេចរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតផ្សេងពីនេះ ។

ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត និងការផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតនៅឃុំ សង្កាត់ ដែលត្រូវបង្កើតថ្មី ដែលត្រូវកែសម្រួលព្រំប្រទល់ តាមលក្ខខណ្ឌដែលកំណត់ដោយច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ត្រូវអនុវត្តតាមបទប្បញ្ញត្តិ និងលក្ខខណ្ឌដែលចែងក្នុងច្បាប់នេះ និងបទបញ្ជា និងនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៤៦.–**

ដើម្បីបោះឆ្នោតបាន ប្រជាពលរដ្ឋត្រូវមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ។

ដើម្បីមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ប្រជាពលរដ្ឋត្រូវបំពេញលក្ខខណ្ឌ ដូចខាងក្រោម ៖

-មានសញ្ជាតិខ្មែរ

-មានអាយុ ១៨ (ដប់ប្រាំបី) ឆ្នាំឡើងទៅ គិតដល់ថ្ងៃបោះឆ្នោត

-មានលំនៅឋាន ឬទីសំណាក់ក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនត្រូវបោះឆ្នោត

-មិនត្រូវស្ថិតក្នុងស្ថានភាពជាប់ពន្ធនាគារ ឬមិនត្រូវបានដកសិទ្ធិបោះឆ្នោត

-ពុំមែនជាជនវិកលចរិត ឬស្ថិតក្រោមអាណាព្យាបាលទូទៅដោយមានលិខិតបញ្ជាក់ពីក្រសួងស្ថាប័នមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចេញបទបញ្ជា និងនីតិវិធីដើម្បីអនុវត្តដាក់ស្តែងនូវមាត្រានេះ ។

**មាត្រា ៤៧.–**

បេក្ខជនដែលឈរឈ្មោះបោះឆ្នោត សហព័ទ្ធ និងកូនអាចទៅបោះឆ្នោតនៅមណ្ឌលបោះឆ្នោតដែលខ្លួនឈរឈ្មោះបោះឆ្នោតបាន ។

បេក្ខជនដែលមានឈ្មោះក្នុងបញ្ជីបេក្ខជនរបស់គណបក្សនយោបាយដែលបានអនុម័តយល់ព្រមឲ្យចុះបញ្ជីឈរឈ្មោះដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ដែលបានចុះឈ្មោះបោះឆ្នោតនៅមណ្ឌលបោះឆ្នោតផ្សេងពីមណ្ឌលដែលខ្លួនឈរឈ្មោះបេក្ខជននោះ អាចធ្វើសេចក្តីស្នើសុំមកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតឲ្យចុះឈ្មោះរបស់ខ្លួន ព្រមទាំងសហព័ទ្ធ និងកូនរបស់ខ្លួន ក្នុងករណីមានការយល់ព្រមពីសហព័ទ្ធ និងកូនរបស់ខ្លួននៅការិយាល័យបោះឆ្នោតណាមួយក្នុងមណ្ឌលដែលខ្លួនឈរឈ្មោះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យលុបឈ្មោះរបស់បេក្ខជនសហព័ទ្ធ និងកូនរបស់បេក្ខជននោះចេញពីបញ្ជីបោះឆ្នោតនៃឃុំ សង្កាត់ ដែលបានចុះឈ្មោះគន្លងមក រួចហើយចាត់ឲ្យចុះឈ្មោះបេក្ខជន សហព័ទ្ធ និងកូនរបស់បេក្ខជននោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោតក្នុងមណ្ឌល ដែលបេក្ខជននោះឈរឈ្មោះតាមការស្នើសុំ ។

**មាត្រា ៤៨.–**

ប្រជាពលរដ្ឋម្នាក់ៗ ត្រូវមានឈ្មោះតែមួយក្នុងបញ្ជីឈ្មោះបោះឆ្នោតនៃការិយាល័យបោះឆ្នោតតែមួយគត់ ។

ប្រជាពលរដ្ឋខ្មែរដែលមានលំនៅឋាន ឬ/និងទីសំណាក់ច្រើនជាងមួយកន្លែងក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវជ្រើសរើសយកកន្លែងតែមួយគត់ ដែលជាទីតាំងនៃជីវភាពរស់នៅជាក់ស្តែងរបស់បុគ្គលនោះ ដើម្បីចុះឈ្មោះបោះឆ្នោត ។

លំនៅឋាន គឺជាកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ។

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថា ជាលំនៅឋាន ។ ទីសំណាក់សំដៅលើទីស្ថានដែលបុគ្គលម្នាក់ស្នាក់អាស្រ័យនៅ ឬអាស្រ័យនៅជាក់ស្តែង ក្នុងរយៈពេលជាកំណត់ណាមួយ ។

## មាត្រា ៤៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញបទបញ្ជា និងនីតិវិធីដើម្បីប្រជាពលរដ្ឋដែលពុំមានលំនៅឋានច្បាស់លាស់ ឬចាកចេញពីលំនៅឋានទៅស្នាក់នៅកន្លែងផ្សេងទៀតក្នុងព្រះរាជាណាចក្រកម្ពុជា អាចចុះឈ្មោះបោះឆ្នោតនៅការិយាល័យបោះឆ្នោតក្នុងឃុំ សង្កាត់ ដែលសាមីខ្លួនមានទីសំណាក់នៅក្នុងឃុំ សង្កាត់នោះ ។

## មាត្រា ៥០.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើប្រតិភូកម្មអំណាចដល់ក្រុមប្រឹក្សាឃុំ សង្កាត់ ឱ្យបំពេញតួនាទីជាតំណាងខ្លួន ក្នុងការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតសម្រាប់ឃុំ សង្កាត់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់តាំងក្រុមចុះឈ្មោះបោះឆ្នោតសម្រាប់ឃុំ សង្កាត់នីមួយៗ ដើម្បីជួយគាំទ្រក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការអនុវត្តនូវតួនាទី និងការទទួលខុសត្រូវខាងលើនេះ ។ ក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗ មានប្រធានមួយរូបដែលចាត់តាំងដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អនុប្រធានមួយរូបជាស្មៀនឃុំ សង្កាត់សាមី និងសមាជិកមួយចំនួនតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំស្របតាមច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវដឹកនាំក្រុមចុះឈ្មោះបោះឆ្នោតឱ្យអនុវត្តឱ្យបានត្រឹមត្រូវនូវច្បាប់ស្តីពីការបោះឆ្នោត បទបញ្ជា និងនីតិវិធីសម្រាប់ការបោះឆ្នោត ។

ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវចាត់សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ០១ (មួយ) ទៅ ០២ (ពីរ) រូប ចំពោះឃុំ សង្កាត់ដែលមានសមាជិកក្រុមប្រឹក្សា ០៥ (ប្រាំ) រូប និង ០២ (ពីរ) ទៅ ០៣ (បី) រូប ចំពោះឃុំ សង្កាត់

ណាដែលមានក្រុមប្រឹក្សាចាប់ពី ០៧ (ប្រាំពីរ) រូបឡើងទៅ ឲ្យប្រចាំការពិនិត្យមើលដំណើរប្រព្រឹត្តទៅនៃក្រុមចុះឈ្មោះបោះឆ្នោត ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។ សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ដែលប្រចាំការនេះ មិនទទួលប្រាក់កម្រៃបន្ថែមឡើយ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួងមហាផ្ទៃ អំពីការធ្វើប្រតិភូកម្មអំណាចស្របតាមសមត្ថភាព និងធនធានរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ហើយត្រូវធ្វើការបណ្តុះបណ្តាលកសាងសមត្ថភាព និងផ្គត់ផ្គង់មធ្យោបាយ សម្ភារ ថវិកាសមស្របដល់ក្រុមប្រឹក្សាឃុំ សង្កាត់ និងក្រុមចុះឈ្មោះបោះឆ្នោត ដើម្បីអនុវត្តភារកិច្ចទទួលខុសត្រូវនេះ ។

**មាត្រា ៥១.-**

ក.ដើម្បីចុះឈ្មោះបោះឆ្នោត ប្រជាពលរដ្ឋត្រូវទៅបង្ហាញខ្លួននៅសាលាឃុំ សង្កាត់របស់ខ្លួន ឬទីកន្លែងណាមួយក្នុងឃុំ សង្កាត់ដែលខ្លួនកំពុងរស់នៅតាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ពេលបង្ហាញខ្លួន ប្រជាពលរដ្ឋត្រូវ ៖

-បង្ហាញអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ សម្រាប់សម្គាល់អត្តសញ្ញាណរបស់ខ្លួនដល់ក្រុមចុះឈ្មោះបោះឆ្នោត

-មានសិទ្ធិបោះឆ្នោត ស្របតាមមាត្រា ៤៦ នៃច្បាប់នេះ

-មិនទាន់បានចុះឈ្មោះ ឬបានចុះឈ្មោះបោះឆ្នោតនៅឃុំ សង្កាត់ផ្សេងណាមួយរួចហើយ ឬមិនទាន់បានចុះឈ្មោះនៅកន្លែងណាមួយក្នុងឃុំ សង្កាត់ ។

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ ក្នុងករណីដែលមានប្រជាពលរដ្ឋដែលទទួលមរណភាព ដែលត្រូវបានដកហូតជាបណ្តោះអាសន្ននូវសិទ្ធិបោះឆ្នោត ដែលត្រូវបានលុបឈ្មោះពីបញ្ជីបោះឆ្នោតដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចេញទៅឃុំ សង្កាត់ផ្សេង ហើយមានឯកសារជាស់អាងត្រឹមត្រូវ និងច្បាស់លាស់ ស្មៀនឃុំ សង្កាត់ ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក តាមទម្រង់ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ។ បញ្ជីនេះត្រូវចម្លងជូនលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀប ចំការបោះឆ្នោតរៀងរាល់ ០២ (ពីរ) ខែម្តង ។ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតដូចមានចែងក្នុងមាត្រា ៤៥ នៃច្បាប់នេះ លេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវសហការជាមួយក្រុមចុះឈ្មោះបោះឆ្នោតនៃឃុំ សង្កាត់នីមួយៗដើម្បីលុបឈ្មោះប្រជា-ពលរដ្ឋទាំងនោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។

បន្ទាប់ពីបញ្ជីបោះឆ្នោតត្រូវបានផ្តល់សុពលភាពរួចហើយ ក្នុងករណីមានប្រជាពលរដ្ឋដែលមិនបានចុះឈ្មោះពីមុនមក ដែលទើបដល់អាយុត្រូវបោះឆ្នោត ដែលបានផ្លាស់លំនៅឋាន ឬទីសំណាក់ចូលថ្មី ស្មៀនឃុំ សង្កាត់ ត្រូវស្រង់ឈ្មោះប្រជាពលរដ្ឋទាំងនោះដាក់ក្នុងបញ្ជីមួយដោយឡែក តាមទម្រង់ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ បញ្ជីនេះ ត្រូវចម្លងជូនលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោតរៀងរាល់ ០២ (ពីរ) ខែម្តង ។ ក្នុងរយៈពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រជាពលរដ្ឋទាំងនោះ ត្រូវបំពេញលក្ខខណ្ឌសម្រាប់ការចុះឈ្មោះ ដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃចំណុច ក នៃមាត្រានេះ ។

ក្នុងករណីចាំបាច់ ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវពិភាក្សាជាមួយលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដើម្បីចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះចល័តស្របតាមបទបញ្ជា និងនីតិវិធី ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ខ.ដើម្បីបញ្ជាក់អត្តសញ្ញាណ អាយុ សញ្ជាតិខ្មែរ និងលំនៅឋាន ឬទីសំណាក់ប្រជាពលរដ្ឋ ត្រូវបង្ហាញដោយផ្ទាល់នូវអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួនចំពោះមុខក្រុមចុះឈ្មោះបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋដែលមិនទាន់មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ឬអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួនបានខូច ឬបាត់ ប្រជាពលរដ្ឋនោះត្រូវរាយការណ៍ជាបន្ទាន់ជូនអាជ្ញាធរមានសមត្ថកិច្ច ដើម្បីបំពេញបែបបទផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរជូន ។

ក្នុងករណីដែលអាជ្ញាធរមានសមត្ថកិច្ចមិនអាចផ្តល់អត្តសញ្ញាណប័ណ្ណសញ្ជាតិ ខ្មែរជូនបានទាន់ពេលវេលា ប្រជាពលរដ្ឋនោះត្រូវមកបង្ហាញខ្លួនដោយផ្ទាល់ចំពោះមុខអាជ្ញាធរឃុំ សង្កាត់ដែលសាមីខ្លួនកំពុងស្នាក់នៅ ដោយនាំមកនូវសាក្សី ០២ (ពីរ) រូប ដែលមានសិទ្ធិបោះឆ្នោត និងមានលំនៅឋាន ឬទីសំណាក់ពិតប្រាកដក្នុងឃុំ សង្កាត់ជាមួយ ដើម្បីអាជ្ញាធរឃុំ សង្កាត់បំពេញបែបបទផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណជូន ។

ឯកសារបញ្ជាក់អត្តសញ្ញាណខាងលើនេះ ត្រូវបិទរូបថតសាមីខ្លួន និងត្រូវបញ្ជាក់អំពីនាមត្រកូល នាមខ្លួន ភេទ ថ្ងៃខែឆ្នាំកំណើត សញ្ជាតិ និងលំនៅឋាន ឬទីសំណាក់របស់សាមីខ្លួន និងសាក្សីទាំង ០២ (ពីរ) រូប ព្រមទាំងស្នាមមេដៃស្តាំរបស់សាមីខ្លួន និងស្នាមមេដៃស្តាំរបស់សាក្សីទាំង ០២ (ពីរ) រូប ។

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញសេចក្តីណែនាំរួមអំពីបែបបទ នីតិវិធីនៃការផ្តល់ឯកសារ បញ្ជាក់អត្តសញ្ញាណដូចបានកំណត់ក្នុងកថាខណ្ឌទី ៣ នៃចំណុច ខ នៃមាត្រានេះ ។

គ.ប្រជាពលរដ្ឋដែលមានលំនៅឋាន ឬទីសំណាក់ផ្សេងពីលំនៅឋាន ឬទីសំណាក់ដែលបានចុះក្នុងអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ប្រជាពលរដ្ឋនោះ ត្រូវនាំមកបង្ហាញដោយផ្ទាល់ ចំពោះ

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ក្រុមចុះឈ្មោះបោះឆ្នោតនូវសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារច្បាប់ដើម ដែលមានចុះនាមត្រកូល នាមខ្លួន ភេទ សញ្ជាតិ និងថ្ងៃ ខែ ឆ្នាំកំណើតរបស់ប្រជាពលរដ្ឋនោះ ក្នុងសៀវភៅនោះ ។

ក្នុងករណីដែលប្រជាពលរដ្ឋមិនទាន់មានសៀវភៅស្នាក់នៅ ឬសៀវភៅគ្រួសារប្រជាពលរដ្ឋនោះ អាចស្នើសុំលិខិតបញ្ជាក់ទីលំនៅពីអាជ្ញាធរឃុំសង្កាត់ ដែលសាមីខ្លួនមានលំនៅឋាន ឬទីសំណាក់ ។ អាជ្ញាធរឃុំ សង្កាត់ ត្រូវចេញលិខិតបញ្ជាក់ទីលំនៅនេះជូនប្រជាពលរដ្ឋឲ្យបានទាន់ពេលវេលានៃការចុះឈ្មោះបោះឆ្នោត ស្របតាមនីតិវិធីនិងលិខិតបទដ្ឋានគតិយុត្តកំណត់ ។

ឃ.ក្នុងករណីដែលប្រជាពលរដ្ឋមានឯកសារគ្រប់គ្រាន់ត្រឹមត្រូវ ដូចមានចែងក្នុងចំណុច ខ និងចំណុច គ នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោតត្រូវ ៖

-ចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីឈ្មោះបោះឆ្នោត

-កត់ឈ្មោះប្រជាពលរដ្ឋនោះ ចូលក្នុងសៀវភៅបញ្ជីបោះឆ្នោត

-ចេញបង្កាន់ដៃបញ្ជាក់អំពីការចុះឈ្មោះជូនសាមីខ្លួន

-បញ្ជាក់ប្រាប់ប្រជាពលរដ្ឋ អំពីការិយាល័យបោះឆ្នោតដែលប្រជាពលរដ្ឋនោះ ត្រូវទៅបោះឆ្នោត ។

ចំពោះប្រជាពលរដ្ឋណាដែលមានឈ្មោះក្នុងសៀវភៅបញ្ជីបោះឆ្នោតរួចហើយ ក្រុមចុះឈ្មោះបោះឆ្នោត គ្រាន់តែពិនិត្យភស្តុតាងនៃការចុះឈ្មោះរបស់ជននោះ ប្រសិនបើជននោះមិនស្ថិតក្នុងករណីណាមួយដូចបានចែងក្នុងកថាខណ្ឌទី ៣ នៃចំណុច ក នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោត ត្រូវធ្វើបច្ចុប្បន្នភាពឈ្មោះរបស់ជននោះ ចូលក្នុងបញ្ជីបោះឆ្នោត ។

## មាត្រា ៥២.-

ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហាមឃាត់មិនឲ្យយកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវ ព្រមទាំងវត្ថុប្រកបដោយគ្រោះថ្នាក់ផ្សេងៗ ចូលក្នុងសាលាឃុំ សង្កាត់ ឬទីកន្លែងកំណត់ សម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត ។

ក្នុងករណី មានជនណាបង្កការអុកឡុកវឹកវរ ក្រុមចុះឈ្មោះបោះឆ្នោត ត្រូវស្នើសុំអន្តរាគមន៍ជាបន្ទាន់ពីអាជ្ញាធរមានសមត្ថកិច្ច ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធានាឲ្យដំណើរការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតប្រព្រឹត្តទៅប្រកបដោយសុវត្ថិភាព និងគ្មានការភ័យខ្លាច ឬការបំភិតបំភ័យនានា ។

## មាត្រា ៥៣.-

ក្នុងដំណើរការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ក្នុងករណីមានភស្តុតាងបញ្ជាក់ថាជនណាដែលពុំមានលក្ខណសម្បត្តិគ្រប់គ្រាន់តាមមាត្រា ៤៦ និងចំណុច ក ចំណុច ខ និងចំណុច គ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

នៃមាត្រា ៥១ នៃច្បាប់នេះ ក្រុមចុះឈ្មោះបោះឆ្នោតត្រូវបដិសេធការចុះឈ្មោះបោះឆ្នោតរបស់ជននោះ ដោយត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធ ០១ (មួយ) ច្បាប់ ជូនសាមីខ្លួន ។

-ផ្តល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា៥៤នៃច្បាប់នេះ សាមីខ្លួន ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួនក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធ ០១ (មួយ) ច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតតាមរយៈលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

**មាត្រា ៥៤.-**

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួនត្រូវបានបដិសេធដោយក្រុមចុះឈ្មោះបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់របស់ខ្លួន ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

**មាត្រា ៥៥.-**

ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវធ្វើការប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ានេះ ដោយសម្លេងភាគច្រើនដាច់ខាតនៃសមាជិកក្រុមប្រឹក្សាទាំងមូល ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

**មាត្រា ៥៦.-**

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់យល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ាក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោត អនុវត្តការចុះឈ្មោះតាមលក្ខខណ្ឌ ដូចមានចែងក្នុងចំណុច យ នៃមាត្រា ៥១ នៃច្បាប់នេះ ។

ប្រសិនបើក្រុមប្រឹក្សាឃុំ សង្កាត់ ពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃការបដិសេធ ០១ (មួយ) ច្បាប់ជូនសាមីខ្លួន ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

-ផ្តល់ព័ត៌មានជូនសាមីខ្លួនថា អនុលោមតាមមាត្រា ៥៧ នៃច្បាប់នេះ សាមីខ្លួន ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

-ផ្ញើសំណុំឯកសារបដិសេធ ០១ (មួយ) ច្បាប់ទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត តាមរយៈលេខាធិការដ្ឋានគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

## មាត្រា ៥៧.-

ជនណាដែលបណ្តឹងតវ៉ារបស់ខ្លួនត្រូវបានបដិសេធដោយក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតបដិសេធ ។

## មាត្រា ៥៨.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើបណ្តឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះអ្នកដែលត្រូវបានបដិសេធដោយអនុវត្តលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតពុំយល់ព្រមតាមសំណើរបស់អ្នកប្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវ ៖

-ចេញសេចក្តីសម្រេចបដិសេធដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងសេចក្តីសម្រេចបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅអ្នកប្តឹងតវ៉ា ។

-ផ្តល់ព័ត៌មានទៅសាមីខ្លួនថា អនុលោមតាមមាត្រា ៥៩ នៃច្បាប់នេះ សាមីខ្លួន ឬតំណាង អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លង សេចក្តីសម្រេចបដិសេធ ។

-ផ្ញើសេចក្តីចម្លងសេចក្តីសម្រេចបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

**មាត្រា ៥៩.-**

ជនណាដែលការសុំចុះឈ្មោះរបស់ខ្លួន ត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬតំណាងអាចប្ដឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្ដីចម្លងសេចក្ដីសម្រេចបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្ដឹងតវ៉ានេះ ដោយបើកសវនាការជាសាធារណៈ ក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្ដឹង ។

ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រម ឬមិនយល់ព្រមតាមបណ្ដឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

-ចេញសេចក្ដីសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬបដិសេធឈ្មោះអ្នកដែលមានបញ្ហា ។

-ផ្ញើសេចក្ដីចម្លងសេចក្ដីសម្រេចយល់ព្រម ឬបដិសេធនេះ ០១ (មួយ) ច្បាប់ទៅអ្នកប្ដឹងតវ៉ា ឬតំណាង ។

ប្រសិនបើសេចក្ដីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ តម្រូវឲ្យចុះឈ្មោះអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះអ្នកដែលមានបញ្ហានោះ តាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះ ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

**មាត្រា ៦០.-**

បន្ទាប់ពីថ្ងៃបញ្ឈប់ការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត ហើយការប្ដឹងតវ៉ាទៅនឹងការចុះឈ្មោះត្រូវបានដោះស្រាយរួចរាល់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបញ្ចូលឈ្មោះ និងទិន្នន័យអ្នកចុះឈ្មោះបោះឆ្នោតថ្មីទៅក្នុងប្រព័ន្ធផ្ទុកទិន្នន័យបញ្ជីឈ្មោះអ្នកបោះឆ្នោតតាមឃុំ សង្កាត់ ឬរាជធានី ខេត្ត ឬមជ្ឈមណ្ឌលផ្ទុកទិន្នន័យបញ្ជីបោះឆ្នោតទូទាំងប្រទេសរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរកឃើញជនណាដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះជននោះ ពីបញ្ជីបោះឆ្នោតច្រើនកន្លែងនោះ ដោយរក្សាទុកឈ្មោះជននោះតែមួយគត់នៅឃុំ សង្កាត់ចុងក្រោយដែលសាមីខ្លួនបានចុះឈ្មោះបោះឆ្នោត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បន្ទាប់ពីបានពិនិត្យផ្ទៀងផ្ទាត់បញ្ជីឈ្មោះបោះឆ្នោតក្នុងប្រព័ន្ធផ្ទុកទិន្នន័យរួច គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យបិទផ្សាយជាសាធារណៈនូវបញ្ជីបោះឆ្នោតដំបូង រួមនឹងបញ្ជីឈ្មោះអ្នកបោះឆ្នោតដែលនឹងត្រូវលុបចេញពីបញ្ជីបោះឆ្នោតដោយមូលហេតុ ដូចមានចែងក្នុងកថាខណ្ឌទី ៣ នៃចំណុច ក នៃមាត្រា ៥១ នៃច្បាប់នេះ និងបញ្ជីឈ្មោះអ្នកដែលមានឈ្មោះច្រើនជាងមួយកន្លែង ហើយដែលនឹងត្រូវលុបចេញតាមឃុំ សង្កាត់នីមួយៗ នៅសាលាឃុំ សង្កាត់ និងទីតាំងណាមួយក្នុងឃុំ សង្កាត់ តាមការកំណត់របស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងនេះបាន ដោយបង់ថ្លៃ ។ តម្លៃនេះត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

## មាត្រា ៦១.-

ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ជនណាក៏ដោយ ក៏អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាឃុំ សង្កាត់ របស់ខ្លួនពីការបាត់បង់ឈ្មោះ ឬជំទាស់ការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃជនណាម្នាក់ដែលខ្លួនមានភស្តុតាងបញ្ជាក់ថា ៖

-ជននោះពុំមានលក្ខខណ្ឌត្រឹមត្រូវគ្រប់គ្រាន់តាមមាត្រា ៤៦ និងមាត្រា ៥១ នៃច្បាប់នេះ ។

-ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោតច្រើនជាងមួយកន្លែង ។

-ជននោះបានមកចុះឈ្មោះ មានបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែជននោះគ្មានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

-ជននោះត្រូវបានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតលុបឈ្មោះមិនត្រឹមត្រូវ ។

-ជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត តែកត់ត្រាមិនច្បាស់លាស់ ។

អ្នកប្តឹងតវ៉ាត្រូវបង្ហាញភស្តុតាងជាឯកសារណាមួយទៅក្រុមប្រឹក្សាឃុំ សង្កាត់ ។

អ្នកប្តឹងជំទាស់ត្រូវផ្តល់ព័ត៌មានបន្ថែម ក្នុងករណីមានការស្នើសុំពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

នៅឆ្នាំដែលមានការរៀបចំការបោះឆ្នោតជាសកល ការប្តឹង ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ មានរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបិទផ្សាយបញ្ជីបោះឆ្នោតដំបូង ។

## មាត្រា ៦២.-

ក្រុមប្រឹក្សាឃុំ សង្កាត់ ត្រូវប្រជុំសម្រេចជាសាធារណៈលើបណ្តឹងតវ៉ា ឬជំទាស់ក្នុងរយៈពេល ០៣ (បី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នេះជាការត្រឹមត្រូវ ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោត ធ្វើការចុះឈ្មោះ ឬកែតម្រូវទិន្នន័យអ្នកដែលមានបញ្ហានោះក្នុងបញ្ជីបោះឆ្នោត ឬលុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហាពុំពេញចិត្តនឹងការសម្រេចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងរយៈពេល ០៥ (ប្រាំ)ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីក្រុមប្រឹក្សាឃុំ សង្កាត់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ចាត់ឲ្យក្រុមចុះឈ្មោះបោះឆ្នោត ធ្វើការចុះឈ្មោះអ្នកដែលមានបញ្ហានោះ ក្នុងបញ្ជីបោះឆ្នោតតាមលក្ខខណ្ឌដូចមានចែងក្នុងចំណុច ឃ នៃមាត្រា៥១នៃច្បាប់នេះ ឬលុបឈ្មោះអ្នកដែលមានបញ្ហានោះចេញពីបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ឬប្រព័ន្ធផ្ទុកទិន្នន័យបញ្ជីបោះឆ្នោត ។

ប្រសិនបើអ្នកតវ៉ា ឬអ្នកជំទាស់ពុំពេញចិត្តនឹងការសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬតំណាងអាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ០៥ (ប្រាំ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានសេចក្តីចម្លងសេចក្តីសម្រេចបដិសេធពីគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ៦៣.-**

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវសម្រេចលើបណ្តឹងតវ៉ា ឬជំទាស់នោះ ដោយបើកសវនាការជាសាធារណៈក្នុងរយៈពេល ១០ (ដប់) ថ្ងៃយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ។

ប្រសិនបើបណ្តឹងតវ៉ា ឬជំទាស់នោះជាការត្រឹមត្រូវ ក្រុមប្រឹក្សាធម្មនុញ្ញត្រូវ ៖

-ចេញសេចក្តីសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចុះឈ្មោះ ឬបដិសេធឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហា ។

-ផ្ញើសេចក្តីចម្លងនៃសេចក្តីយល់ព្រមឬបដិសេធនេះ ០១ (មួយ) ច្បាប់ ទៅអ្នកប្តឹងតវ៉ា ឬអ្នកជំទាស់ ឬអ្នកដែលមានបញ្ហា ។

ប្រសិនបើសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញតម្រូវឲ្យចុះឈ្មោះអ្នកប្តឹងតវ៉ា ឬអ្នកដែលមានបញ្ហា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបញ្ជាឲ្យក្រុមប្រឹក្សាឃុំ សង្កាត់ ចាត់ឲ្យក្រុម

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

ចុះឈ្មោះបោះឆ្នោតធ្វើការចុះឈ្មោះជននោះ តាមលក្ខខណ្ឌចុះឈ្មោះបោះឆ្នោត ដូចមានចែងក្នុងចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ហើយផ្ញើបញ្ជីបោះឆ្នោតកែប្រែថ្មីនោះ ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

## មាត្រា ៦៤.-

នៅពេលដែលបណ្តឹងតវ៉ា ឬបណ្តឹងជំទាស់ត្រូវបានសម្រេចជាស្ថាពរ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់បញ្ជូនបញ្ជីបោះឆ្នោតផ្លូវការក្នុងឆ្នាំនីមួយៗទៅលេខាធិការដ្ឋានគណៈ-កម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ០១ (មួយ) ច្បាប់ និងសាលាឃុំ សង្កាត់ ០១ (មួយ) ច្បាប់ ដើម្បីរក្សាទុកជាឯកសារផ្លូវការ ។

ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតក្នុងឃុំ សង្កាត់ មានសិទ្ធិស្នើសុំពិនិត្យមើលឈ្មោះរបស់ខ្លួនក្នុងបញ្ជីឈ្មោះបោះឆ្នោតនេះបាន ។

គណបក្សនយោបាយដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ មានសិទ្ធិសុំបញ្ជីបោះឆ្នោតថតចម្លងនេះបានដោយបង់ថ្លៃ ។ តម្លៃនេះ ត្រូវគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

## មាត្រា ៦៥.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចាត់ឲ្យបិទផ្សាយជាសាធារណៈនូវបញ្ជីបោះ-ឆ្នោតផ្លូវការនៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ នៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និងទីស្នាក់ការគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត តាមកាលបរិច្ឆេទដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ៦៦.-

គណបក្សនយោបាយ ឬអង្គការមិនមែនរដ្ឋាភិបាលជាតិ និងបរទេសអង្គការអន្តរជាតិ និងប្រទេសនានាអាចបញ្ជូនភ្នាក់ងារ ឬតំណាងរបស់ខ្លួនចូលសង្កេតការណ៍ក្នុងអំឡុងពេលនៃការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោតជារៀងរាល់ឆ្នាំ ។

ភ្នាក់ងារ ឬតំណាងទាំងអស់ត្រូវមានការទទួលស្គាល់ពីគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

## ជំពូកទី ៧
## ការឃោសនាបោះឆ្នោត

### មាត្រា ៦៧.-

ការឃោសនាបោះឆ្នោតមានទិសដៅឲ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោត ធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួនជូនអ្នកបោះឆ្នោត ។

### មាត្រា ៦៨.-

ការឃោសនាបោះឆ្នោត គឺជាសកម្មភាពមួយចំនួនដែលត្រូវធ្វើជាសាធារណៈ ដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឲ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយ ណាមួយ មានដូចជា ៖

-ការជួបប្រជុំជាសាធារណៈរបស់គណបក្សនយោបាយ ឬបេក្ខជន ។

-ការរៀបចំក្បួនព្យុហយាត្រា ឬក្បួនដំណើរដោយក្រុមថ្មើរជើង ឬដោយយានជំនិះគ្រប់ប្រភេទ នៅរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ យ៉ាងច្រើន ០៤ (បួន) ដង ក្នុងអំឡុងពេលឃោសនាបោះឆ្នោត ។

-ការជួបជុំ ឬការឃោសនាតាមផ្ទះ ។

-ការផ្សព្វផ្សាយតាមវិទ្យុ ឬទូរទស្សន៍ ឬសារព័ត៌មាន ។

-ការផ្សព្វផ្សាយតាមលេកអាកាស ឬការឃោសនាតាមឧបករណ៍បំពងសំឡេង ឬតាមរយៈការចាក់ផ្សាយកាសែ្សតវីដេអូ ឬស៊ីឌី ឬឌីវីឌី ក្នុងរោងវីដេអូសាធារណៈ ឬទីធ្លាសាធារណៈ ។

-សកម្មភាពបិទផ្សាយនូវបដាពាក្យស្លោក ឬកម្មវិធីនយោបាយ ឬរូបភាពឃោសនានានា។

-សកម្មភាពចែកចាយខិតប័ណ្ណគណបក្សនយោបាយ ។

-សកម្មភាពចែកចាយស្លាកសញ្ញាគណបក្សនយោបាយ ឬមួក សម្លៀកបំពាក់ សម្ភារផ្សេងៗទៀត ដែលបោះពុម្ព ឬគូរ ឬផលិតដែលមានស្លាកសញ្ញាគណបក្សនយោបាយ ឬបេក្ខជន ជូនអ្នកបោះឆ្នោត ។

-សកម្មភាពលើកបដានៅទីសាធារណៈណាមួយ ឬ/និងដំឡើងបន្ទះក្តារបិទក្រដាសផ្សាយ ។

-ការប្រគំតន្ត្រីនៅនឹងកន្លែងណាមួយ ឬការច្រៀងចម្រៀងឃោសនា ឬការលេងភ្លេងឃោសនាបោះឆ្នោត ។

-ការរៀបចំកម្មវិធីប្រកួតកីឡា ។

### មាត្រា ៦៩.-

ស្លាកសញ្ញាគណបក្សនយោបាយអាចលើកនៅទីសាធារណៈ ដោយមានការសម្របសម្រួលពីអាជ្ញាធរឃុំ សង្កាត់ ផ្អែកលើគោលការណ៍ស្មើភាព សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង សោភ័ណភាពសាធារណៈ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

ស្លាកសញ្ញាគណបក្សនយោបាយ និងសម្ភារឃោសនារបស់គណបក្សនយោបាយ មិនត្រូវបានអនុញ្ញាតឲ្យលើក ឬបិទនៅក្នុងបរិវេណ ឬលើអគារ ឬការិយាល័យរបស់រដ្ឋ ។

ហាមគណបក្សនយោបាយលើក ឬបិទស្លាកសញ្ញាគណបក្សនយោបាយ បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិតប័ណ្ណនៅតាមលំនៅឋានរបស់ប្រជាពលរដ្ឋ ប្រសិនមិនមានការយល់ព្រមជាមុនពីម្ចាស់លំនៅឋាន ។ ប្រជាពលរដ្ឋជាម្ចាស់លំនៅឋានមានសិទ្ធិសម្រេចលើក ឬបិទ ឬមិនលើក ឬមិនបិទ ស្លាកសញ្ញា បដាឃោសនា រូបសញ្ញាឃោសនា ពាក្យស្លោក ខិតប័ណ្ណរបស់គណបក្សណាមួយបាន ។

ស្លាកសញ្ញាគណបក្សនយោបាយ ឬសម្ភារឃោសនារបស់គណបក្សនយោបាយ ដែលស្ថិតនៅក្នុងរង្វង់ ១០០ (មួយរយ) ម៉ែត្រ ពីការិយាល័យបោះឆ្នោត ត្រូវយកចេញយ៉ាងយូរបំផុតនៅថ្ងៃបញ្ចប់ការឃោសនាបោះឆ្នោត លើកលែងតែស្លាកសញ្ញាដែលមាននៅទីស្នាក់ការអចិន្ត្រៃយ៍របស់គណបក្សនយោបាយ ។

គណបក្សនយោបាយត្រូវប្រមូលយកមកវិញនូវប័ណ្ណប្រកាស ឬប័ណ្ណបិទផ្សាយ បដា ឯកសារឃោសនាទាំងអស់របស់ខ្លួនពីគ្រប់កន្លែងសាធារណៈក្នុង រយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ បន្ទាប់ពីថ្ងៃបោះឆ្នោត ។

**មាត្រា ៧០.-**

ការស្លៀកសម្លៀកបំពាក់ ឬ/និងពាក់មួក ដែលតាំងបង្ហាញឲ្យឃើញនូវរូបសញ្ញា ឬសារនយោបាយរបស់គណបក្សនយោបាយ ឬរូបថតបេក្ខជនណាម្នាក់ មិនរាប់បញ្ចូលទៅក្នុងសកម្មភាពឃោសនាបោះឆ្នោតឡើយ លើកលែងតែការស្លៀកពាក់នោះស្ថិតក្នុងការិយាល័យបោះឆ្នោត ឬស្ថិតក្នុងបរិវេណខាងក្នុង ឬបរិវេណខាងក្រៅនៃការិយាល័យបោះឆ្នោត ក្នុងថ្ងៃបោះឆ្នោត ។

**មាត្រា ៧១.-**

គណបក្សនយោបាយ និងបេក្ខជនទាំងអស់ត្រូវចៀសវាងប្រព្រឹត្តអំពើគំរាមកំហែង ឬបំភិតបំភ័យ ឬអំពើហិង្សាទៅលើប្រជាពលរដ្ឋ ទៅលើគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

គ្រប់គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវញុះញង់អ្នកគាំទ្រ ឬអ្នកបោះឆ្នោតឲ្យប្រព្រឹត្តអំពើរំលោភ គំរាមកំហែង អំពើហិង្សា ឬបំភិតបំភ័យទៅលើបុគ្គល ឬគណបក្សនយោបាយដទៃទៀតឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវនិយាយដោយផ្ទាល់មាត់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរក្នុងន័យអសីលធម៌ ប្រមាថ មាក់ងាយទៅលើបេក្ខជនអ្នកគាំទ្រ ឬលើបុគ្គលណាមួយឡើយ ។

ROYAUME du CAMBODGE
LE MINISTERE du PALAIS ROYAL

គ្រប់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រទាំងអស់មិនត្រូវធ្វើការគំរាមកំហែង បំភិតបំភ័យ និងលួងលោមឲ្យបុគ្គលផ្តិតមេដៃ ឬស្បថ ឬសន្យាបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយឡើយ ។

គ្រប់គណបក្សនយោបាយ បេក្ខជន ឬតំណាងទាំងអស់មិនត្រូវផ្តល់អំណោយជាថវិកា ឬជាសម្ភារដែលជាវង្វាន់លើកទឹកចិត្ត ទោះបីតាមមធ្យោបាយ ឬរូបភាពណាក៏ដោយ ដល់ស្ថាប័ន អង្គការ ឬបុគ្គលណាម្នាក់ ក្នុងគោលបំណងទិញទឹកចិត្តអ្នកបោះឆ្នោត ។

**មាត្រា ៧២.-**

យុទ្ធនាការឃោសនាបោះឆ្នោតមានរយៈពេល ២១ (ម្ភៃមួយ) ថ្ងៃ ហើយគ្រប់សកម្មភាពនៃការឃោសនាបោះឆ្នោតត្រូវចប់ ២៤ (ម្ភៃបួន) ម៉ោង មុនថ្ងៃបោះឆ្នោត ។

រាល់ការស្ទង់មតិ និងការផ្សព្វផ្សាយលទ្ធផលនៃការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវបញ្ឈប់ ០៧ (ប្រាំពីរ) ថ្ងៃ មុនថ្ងៃបោះឆ្នោត ។ ការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត គឺជាការប្រើសំណាកដែលបានជ្រើសរើស ឬ/និងបញ្ជីសំណួរ ដើម្បីស្រង់មតិរបស់ប្រជាពលរដ្ឋអំពីការបោះឆ្នោត ។ រាល់ការរៀបចំការស្ទង់មតិពាក់ព័ន្ធកិច្ចការបោះឆ្នោត ត្រូវគោរពតាមគោលការណ៍ ដូចខាងក្រោម ៖

-ដំណើរការប្រកបដោយតម្លាភាព និងភាពមិនលម្អៀង

-រៀបចំឡើងដោយអង្គការ ឬស្ថាប័នដែលមានវិជ្ជាជីវៈ

-ការគោរពសិទ្ធិ សេរីភាពរបស់បុគ្គល

-រក្សាការសម្ងាត់នៃការបោះឆ្នោតរបស់អ្នកបោះឆ្នោត

-ការមិនបង្កឲ្យមានអសន្តិសុខ ភាពចលាចល ឬប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ ឬការធ្វើឲ្យភាន់ច្រឡំក្នុងដំណើរការបោះឆ្នោត

-លទ្ធផលដែលបានមកពីការស្ទង់មតិ ត្រូវផ្តល់ជូនគណបក្សនយោបាយ និងផ្សព្វផ្សាយជូនសាធារណជនដោយស្មើភាព ។

**មាត្រា ៧៣.-**

គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវចាប់ផ្តើម ពីម៉ោង ០៦ (ប្រាំមួយ) ព្រឹក ដល់ម៉ោង ១០ (ដប់) យប់ ។

គ្រប់សកម្មភាពឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយ ត្រូវឈប់សម្រាកនៅចន្លោះពីម៉ោង ១០ (ដប់) យប់ ដល់ម៉ោង ០៦ (ប្រាំមួយ) ព្រឹក ។

សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់ចាប់ពីម៉ោង ១២ (ដប់ពីរ) ថ្ងៃត្រង់ ដល់ម៉ោង ០២ (ពីរ) រសៀល ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

សកម្មភាពឃោសនាដោយឧបករណ៍បំពងសំឡេង ត្រូវហាមឃាត់នៅក្បែរ មន្ទីរពេទ្យ ឬក្បែរ សាលារៀន ឬគ្រឹះស្ថានសិក្សានានា ក្នុងពេលម៉ោងសិស្សកំពុងសិក្សា ។

**មាត្រា ៧៤.-**

ក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត គណបក្សនយោបាយទាំងអស់ បេក្ខជនទាំងអស់ សមាជិកនៃគណបក្សនយោបាយទាំងអស់ អ្នកគាំទ្រទាំងអស់ ត្រូវគោរពតាមវិធាន បទប្បញ្ញត្តិ និងគោលការណ៍ ដែលចែងក្នុងច្បាប់បោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ និងក្រមសីលធម៌ បទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត គោរពតាមគោលការណ៍សិទ្ធិមនុស្ស និងលទ្ធិប្រជាធិបតេយ្យ ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។

របៀប បែបបទប្ដឹងជំទាស់ ឬតវ៉ាក្នុងពេលឃោសនាបោះឆ្នោត និងការដោះស្រាយពាក្យបណ្ដឹង ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។ ក្រុមប្រឹក្សាធម្មនុញ្ញមានសមត្ថកិច្ចសម្រេចសេចក្ដីចុងក្រោយ ។

**មាត្រា ៧៥.-**

គ្រប់ប្រព័ន្ធផ្សព្វផ្សាយព័ត៌មាន រួមមានសារព័ត៌មាន វិទ្យុ និងទូរទស្សន៍របស់រដ្ឋត្រូវចុះផ្សាយគ្រប់ព័ត៌មានដែលស្នើដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយមិនយកថ្លៃ ដើម្បីផ្សព្វ-ផ្សាយពីការងារបោះឆ្នោត និងអប់រំដល់អ្នកបោះឆ្នោត ។

**មាត្រា ៧៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់វិធានការ ដើម្បីផ្សព្វផ្សាយអត្ថបទឃោសនាតាមសំណើរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ផ្អែកតាមគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ ។

**មាត្រា ៧៧.-**

ក្នុងការអនុវត្តសិទ្ធិផ្សព្វផ្សាយ គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវប្រើអំពើហិង្សា អំពើរំលោភ សំដីប្រមាថមើលងាយ មិនត្រូវសាបព្រោះឲ្យមានការភ័យខ្លាច ការភាន់ច្រឡំ ធ្វើឲ្យច្របូកច្របល់បាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

**មាត្រា ៧៨.-**

អ្នកគ្រប់គ្រងរោងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈត្រូវផ្ដល់ទីកន្លែងរបស់ខ្លួនដល់បេក្ខជន ឬគណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត ដែល

សុំជួលប្រើប្រាស់សម្រាប់បម្រើការឃោសនាដោយផ្អែកលើគោលការណ៍ស្មើភាព និងតាមលំដាប់ពេលមុនក្រោយ ។

**មាត្រា ៧៩.-**

ក្នុងសម័យឃោសនាបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គណបក្សនយោបាយ ឬបេក្ខជនដែលមានបំណងជួលពេងមហោស្រព មណ្ឌលកីឡា ឧទ្យានសាធារណៈ សាលសាធារណៈ ដូចមានចែងក្នុងមាត្រា ៧៨ នៃច្បាប់នេះ ត្រូវធ្វើពាក្យសុំទៅអ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ០៣ (បី) ថ្ងៃយ៉ាងតិចមុនថ្ងៃប្រជុំឃោសនា ហើយត្រូវចម្លងពាក្យសុំនេះ ០១ (មួយ) ច្បាប់ ផ្ញើទៅគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

អ្នកគ្រប់គ្រងទីកន្លែងទាំងនោះ ត្រូវឆ្លើយតបនឹងពាក្យសុំជួលក្នុងរយៈពេល ២៤ (ម្ភៃបួន) ម៉ោងយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យសុំ ។

**មាត្រា ៨០.-**

ហាមប្រើប្រាស់ថវិកា សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាបោះឆ្នោតឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជន ណាម្នាក់ និងការប្រើប្រាស់មធ្យោបាយដឹកជញ្ជូនដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីដឹកជញ្ជូនអ្នកបោះឆ្នោតទៅកាន់ការិយាល័យបោះឆ្នោត ។

**មាត្រា ៨១.-**

គណបក្សនយោបាយ ឬបេក្ខជនអាចធ្វើសកម្មភាពឃោសនានៅលើទីធ្លាឯកជន ឬនៅសាលឯកជនបាន ប្រសិនបើមានការព្រមព្រៀងពីម្ចាស់កន្លែងនោះ តែត្រូវជូនដំណឹងដល់គណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ។

**មាត្រា ៨២.-**

មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ មិនត្រូវ ៖

-ប្រើឥទ្ធិពល អំណាចនៃតួនាទីរបស់ខ្លួនដោយប្រយោល ឬចំពោះ ទៅលើដំណើរការបោះឆ្នោត ដូចជាការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬជាលាយលក្ខណ៍អក្សរ ដែលមានន័យគំរាមកំហែងដល់អាយុជីវិត រូបរាងកាយ ឬការប៉ុនប៉ងបំផ្លិចបំផ្លាញ ធ្វើឱ្យខូចខាតទ្រព្យសម្បត្តិ ការដាក់បង្ខាញ ឬប្រើប្រាស់នូវគ្រឿងសព្វាវុធ ដើម្បីបំភិតបំភ័យ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-ប្រើប្រាស់អគារ ឬការិយាល័យរបស់រដ្ឋ ដើម្បីឃោសនាបោះឆ្នោត ស្វែងរកសំឡេងឆ្នោតឲ្យគណបក្សនយោបាយ ឬបេក្ខជនណាមួយ

-ចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត សម្រាប់គណបក្សនយោបាយ ឬបេក្ខជនណាមួយឡើយ។

ការចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោត ដែលត្រូវបានហាមឃាត់ចំពោះមន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុងបំពេញភារកិច្ច ត្រូវបានកំណត់ដូចតទៅ ៖

- ជាសមាជិកនៃគណៈកម្មការអេចិន្ត្រៃយ៍ផ្នែកព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយ ឬគណៈ-កម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។
- ការជួបជុំ ឬការចូលរួមក្នុងក្បួនដង្ហែ ឬក្បួនព្យុហយាត្រា ដើម្បីគាំទ្រដល់គណបក្សនយោបាយណាមួយ ឬ/និង បេក្ខជនណាម្នាក់ ។
- ការចូលរួមក្នុងការស្ទង់មតិប្រជាពលរដ្ឋ ដែលធ្វើឡើងសម្រាប់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការបើកបរយានជំនិះរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។
- ការធ្វើសកម្មភាពចែកចាយសម្ភារឃោសនាបោះឆ្នោត ដល់អ្នកបោះឆ្នោត ក្នុងគោលបំណងគាំទ្រគណបក្សនយោបាយ ឬ/និងបេក្ខជនណាម្នាក់ ។
- ការធ្វើសេចក្ដីថ្លែងការណ៍ជាសាធារណៈ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។
- ការចូលរួមលេងភ្លេង ឬ/និងច្រៀងចម្រៀង ឬ/និងផ្សព្វផ្សាយសារនយោបាយផ្សេងៗ តាមរយៈឧបករណ៍បំពងសំឡេងនានា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬ/និងបេក្ខជនណាម្នាក់ ។

**មាត្រា ៨៣.-**

បន្ទាប់ពីបញ្ចប់ម៉ោងធ្វើការ ឬស្ថិតនៅក្រៅម៉ោងការងារ ឬមិនស្ថិតក្នុងពេលបំពេញការងារក្នុងសមត្ថភាពផ្លូវការ មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងយោធពលខេមរភូមិន្ទ នគរ-បាលជាតិ និងមន្ត្រីតុលាការ អាចចូលរួមក្នុងសកម្មភាពឃោសនាគាំទ្រចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ប៉ុន្តែមិនត្រូវស្លៀកពាក់ឯកសណ្ឋាន មិនត្រូវមានអាវុធជាប់នឹងខ្លួន និងមិនត្រូវធ្វើអ្វីដែលនាំឲ្យមានការគំរាមកំហែងឡើយ ។

**មាត្រា ៨៤.-**

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការ អន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀងនៅក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងសមាគម ឬអង្គការអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា មិនត្រូវធ្វើសកម្មភាពណាមួយ ទោះដោយផ្ទាល់ក្តី ឬដោយប្រយោលក្តី ដូចខាងក្រោម ៖

-ផ្តួចផ្តើម ឬចូលរួមក្នុងការឃោសនាបោះឆ្នោតរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការផ្តួចផ្តើម ឬការចូលរួមឃោសនា រួមមាន ៖

• ការបញ្ចុះបញ្ចូល ឬការប្រមូលផ្តុំប្រជាពលរដ្ឋឲ្យចូលរួមឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

• ការចូលរួមក្នុងក្បួនដង្ហែ ឬការប្រជុំរបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

• ការចូលរួមផ្សព្វផ្សាយគោលនយោបាយ ឬសម្ភារឃោសនាបោះឆ្នោត របស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

• ការចូលជាសមាជិកគណៈកម្មការឃោសនាបោះឆ្នោតនៃគណបក្សនយោបាយណាមួយ ។

-ចេញសេចក្តីថ្លែងការណ៍ ឬធ្វើសកម្មភាពណាមួយក្នុងគោលបំណងគាំទ្រ ឬបង្ហាញភាពលម្អៀងទៅរក ឬប្រឆាំងនឹងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។ ការចេញសេចក្តីថ្លែងការណ៍ ការធ្វើសកម្មភាពគាំទ្រ ឬការបង្ហាញភាពលម្អៀង រួមមាន ៖

• ការស្ទង់មតិក្នុងគោលបំណងបម្រើឲ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

• ការសរសេរជាលាយលក្ខណ៍អក្សរ ឬផ្តល់បទសម្ភាសន៍ដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងន័យគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

• ការនិយាយដោយផ្ទាល់ ឬដោយប្រយោល ឬសរសេរជាលាយលក្ខណ៍អក្សរ ក្នុងន័យប្រមាថមាក់ងាយគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

• ការដាក់តាំង ឬបិទផ្សាយរូបភាព ឬឯកសារផ្សេងៗ ភ្ជាប់នឹងយានយន្តរបស់អង្គការខ្លួន ឬនៅក្នុងបរិវេណនៃទីកន្លែងធ្វើការរបស់ខ្លួន ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

-ផ្ដល់មធ្យោបាយជាថវិកា សម្ភារៈ បរិក្ខារ ធនធានមនុស្ស ឬមធ្យោបាយផ្សេងៗ ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ដែលរួមមាន ៖

· ការផ្ដល់យានយន្ដគ្រប់ប្រភេទ ដើម្បីជាមធ្យោបាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

· ការផ្ដល់ថវិកា សម្ភារៈ និងបរិក្ខារប្រើប្រាស់ផ្សេងៗជូនប្រជាពលរដ្ឋ សម្រាប់ចូលរួមក្នុងសកម្មភាពឃោសនា ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

· ការផ្ដល់ថវិកា សម្ភារៈ និងបរិក្ខារ សម្រាប់ដង្ហែក្បួនឃោសនា ការជួបជុំជាសាធារណៈ ការសម្ដែងសិល្បៈ និងការបោះពុម្ពសម្ភារឃោសនា ទោះដោយផ្ទាល់ក្ដី ឬប្រយោលក្ដី ដើម្បីគាំទ្រគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

**មាត្រា ៨៥.-**

ហាមជនបរទេសដែលមានវត្តមានក្នុងព្រះរាជាណាចក្រកម្ពុជា ធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងការឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

**មាត្រា ៨៦.-**

គណបក្សនយោបាយ និងបេក្ខជនទាំងអស់មិនត្រូវជ្រៀតជ្រែក ឬធ្វើឲ្យរាំងស្ទះដល់សកម្មភាពគណបក្សនយោបាយ ឬបេក្ខជនដទៃទៀត ។

**មាត្រា ៨៧.-**

អាជ្ញាធរគ្រប់លំដាប់ថ្នាក់ដែលទទួលខុសត្រូវការងារសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងវិស័យការងារឯទៀត ត្រូវផ្ដល់កិច្ចសហប្រតិបត្តិការដល់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ជាដាច់ខាត ដើម្បីរក្សាសុវត្ថិភាព សន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយក្នុងសម័យបោះឆ្នោត ការចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ការឃោសនាបោះឆ្នោត ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលបោះឆ្នោត តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ ។

**មាត្រា ៨៨.-**

ចំណាយសម្រាប់ការឃោសនារបស់គណបក្សនយោបាយ និងរបស់បេក្ខជនម្នាក់ៗជាបន្ទុករបស់គណបក្សនយោបាយ ឬបេក្ខជនផ្ទាល់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ៨៩.-**

គ្រប់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោតរួចហើយ ត្រូវមានសៀវភៅគណនី ដើម្បីកត់ត្រាចំណូល ប្រភពនៃប្រាក់ចំណូល និងចំណាយសម្រាប់ការឃោសនាបោះឆ្នោត ។

**មាត្រា ៩០.-**

វិភាគទានទាំងអស់ដែលគណបក្សនយោបាយបានទទួល ត្រូវបញ្ចូលក្នុងគណនីនៃធនាគារ ហើយរាល់ចំណាយទៅលើការឃោសនា ត្រូវតែចេញពីគណនីតែមួយនេះ ។

**មាត្រា ៩១.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាចត្រួតពិនិត្យសៀវភៅគណនីរបស់គណបក្សនយោបាយដែលបានចុះបញ្ជីឈ្មោះបោះឆ្នោត តាមការចាំបាច់ ។

## ជំពូកទី ៨
## ការបោះឆ្នោត ការរាប់សន្លឹកឆ្នោត
## និងការប្រកាសលទ្ធផលនៃការបោះឆ្នោត

**មាត្រា ៩២.-**

ការិយាល័យបោះឆ្នោតត្រូវរៀបចំតាមការកំណត់ ដូចមានចែងក្នុងមាត្រា ៣៨ និងមាត្រា ៣៩ នៃច្បាប់នេះ ។

**មាត្រា ៩៣.-**

ការបោះឆ្នោតត្រូវធ្វើតែ ០១ (មួយ) ថ្ងៃ ។

ការបោះឆ្នោតប្រព្រឹត្តទៅចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ព្រឹក រហូតដល់ម៉ោង ១៥:០០ (ដប់ប្រាំ) លើកលែងតែមានសេចក្ដីសម្រេចផ្សេងពីនេះរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ប្រសិនបើអ្នកបោះឆ្នោតទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតបានបោះគ្រប់គ្នាហើយ គណៈកម្មការការិយាល័យបោះឆ្នោត អាចប្រកាសបញ្ចប់ការបោះឆ្នោត មុនម៉ោង ១៥:០០ (ដប់ប្រាំ) ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវប្រកាសបិទ ការបោះឆ្នោតនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

ជនគ្រប់រូបដែលមានបំណងបោះឆ្នោត មិនត្រូវអនុញ្ញាតឲ្យចូលបរិវេណខាងក្នុងក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ឡើយ ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL

ជនដែលមានសិទ្ធិបោះឆ្នោតក្រោយម៉ោង ១៥:០០ (ដប់ប្រាំ) ហើយអាចអនុញ្ញាតឲ្យបោះ-ឆ្នោត គឺជាជនដែលស្ថិតនៅក្នុងការិយាល័យបោះឆ្នោត ឬក្នុងបរិវេណខាងក្នុងនៅម៉ោង ១៥:០០ (ដប់ប្រាំ) ។

**មាត្រា ៩៤.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយបញ្ជីឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោត ហើយត្រូវបិទផ្សាយបញ្ជីទាំងនេះនៅគ្រប់ការិយាល័យបោះឆ្នោត ៣០ (សាមសិប) ថ្ងៃ យ៉ាងតិច មុនថ្ងៃបោះឆ្នោត ។

**មាត្រា ៩៥.-**

គណបក្សនយោបាយដែលបានចុះបញ្ជីឈរឈ្មោះបោះឆ្នោត អាចសុំសេចក្ដីចម្លងនៃបញ្ជីឈ្មោះ និងទីតាំងការិយាល័យបោះឆ្នោតនេះ ដោយបង់ថ្លៃ ។ តម្លៃគិតត្រឹមតែតម្លៃផលិតប៉ុណ្ណោះ ។

**មាត្រា ៩៦.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវផ្ដល់ជូនការិយាល័យបោះឆ្នោតនីមួយៗនូវសម្ភារដូចតទៅ តាមចំនួនសមស្រប ០១ (មួយ) ថ្ងៃមុន ថ្ងៃបោះឆ្នោត ៖

១- បញ្ជីបោះឆ្នោត ។
២- សន្លឹកឆ្នោតមិនទាន់ប្រើប្រាស់ ។
៣- ហិបឆ្នោត ។
៤- បន្ទប់សម្ងាត់ ។
៥- ត្រាសម្ងាត់សម្រាប់បោះលើសន្លឹកឆ្នោត ។
៦- ទឹកជ្រលក់សម្រាប់សម្គាល់ថាបានបោះឆ្នោតហើយ ។
៧- សោ និងប្រដាប់ឃ្លុំ ។
៨- ក្រដាសបែបបទសម្រាប់បំពេញកំណត់ហេតុ និងសម្រង់លទ្ធផល ។
៩- ប៊ិចសរសេរដែលមានគុណភាពល្អ ។
១០- ស្រោមសំបុត្រដែលបោះពុម្ពលើខ្នងរួចហើយ ។
១១- ថង់ប្លាស្ទិក ។
១២- សម្ភារ និងបរិក្ខារចាំបាច់ផ្សេងៗទៀត ។

ROYAUME DU CAMBODGE · MINISTÈRE DU PALAIS ROYAL

**មាត្រា ៩៧.-**

មុនថ្ងៃបោះឆ្នោត ០១ (មួយ) ថ្ងៃ ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវប្រជុំសមាជិកទាំងអស់ដើម្បីត្រួតពិនិត្យវត្តមានសមាជិក និងពិនិត្យទីតាំងការិយាល័យបោះឆ្នោត និងពិនិត្យសម្ភារបរិក្ខារបម្រើឲ្យការងារបោះឆ្នោត ។

ប្រសិនបើមានសមាជិកណាម្នាក់អវត្តមាន សមាជិកនោះត្រូវជំនួសដោយសមាជិកថ្មីដែលជ្រើសតាំងឡើង ស្របតាមបទប្បញ្ញត្តិដែលចែងក្នុងបទបញ្ជា និងនីតិវិធី ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវចាត់ការ ដើម្បីឲ្យការិយាល័យបោះឆ្នោតមានសម្ភារ បរិក្ខារ និងសង្ហារិមចាំបាច់សម្រាប់ការបោះឆ្នោត ។

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ពិនិត្យស្ថានភាពសន្តិសុខនៅការិយាល័យបោះឆ្នោត ហើយចាត់វិធានការ ការពារសន្តិសុខ ប្រសិនបើចាំបាច់ ។

**មាត្រា ៩៨.-**

នៅថ្ងៃបោះឆ្នោត សមាជិកគណៈកម្មការការិយាល័យបោះឆ្នោតត្រូវមកដល់ទីតាំងការិយាល័យបោះឆ្នោត ដើម្បីរៀបចំការបោះឆ្នោតយ៉ាងយូរនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក ។

ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ត្រូវបានអនុញ្ញាត ឲ្យចូលក្នុងការិយាល័យបោះឆ្នោតនៅម៉ោង ៦:០០ (ប្រាំមួយ) ព្រឹក ។

គណៈកម្មការការិយាល័យបោះឆ្នោត ត្រូវផ្ទៀងផ្ទាត់ភាពត្រឹមត្រូវនៃភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍មុននឹងអនុញ្ញាតឲ្យអ្នកទាំងនេះចូលក្នុងការិយាល័យបោះឆ្នោត ។

**មាត្រា ៩៩.-**

នៅចន្លោះពីម៉ោង ៦:០០នាទីព្រឹក ដល់ម៉ោង ៦:៣០នាទីព្រឹក នៅថ្ងៃបោះឆ្នោត មន្ត្រីការិយាល័យបោះឆ្នោត ត្រូវរៀបចំកិច្ចការ ដូចខាងក្រោម ៖

-ពិនិត្យឡើងវិញនូវហិបឆ្នោតដែលបានផ្តល់ឲ្យ និងពិនិត្យផ្លាកលេខ ឬសញ្ញាសម្គាល់ហិបឆ្នោតឲ្យបានត្រឹមត្រូវ

-បង្ហាញអ្នកនៅក្នុងការិយាល័យបោះឆ្នោតថា ហិបឆ្នោតនីមួយៗពុំមានអ្វីក្នុងនោះឡើយ

-បិទគម្របក្នុងនៃហិបឆ្នោត ហើយចាក់សោឃ្លុំ

-បិទផ្លាកលេខ ឬសញ្ញាសម្គាល់ជាប់នឹងហិបឆ្នោត ដោយមានបោះត្រារបស់ការិយាល័យបោះឆ្នោតពីលើ

-អនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ពិនិត្យមើលហិបឆ្នោត ផ្លាកលេខ ឬសញ្ញាសម្គាល់ផ្សេងៗដែលបិទលើហិបឆ្នោត

-តុ និងកៅអីសម្រាប់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍នៅខាងឆ្វេងដៃតុរបស់ប្រធាន ឬ/និងនៅខាងក្រោយតុអនុប្រធាន និងលេខាធិការ ប្រសិនបើមាន ។

ក្នុងករណីសម្ភារ ឧបករណ៍បោះឆ្នោតត្រូវបានប្រគល់ឲ្យការិយាល័យបោះឆ្នោតក្រោយម៉ោង ៦:៣០ នាទីព្រឹក ពេលទទួល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោតត្រូវអនុវត្តតាមនីតិវិធីខាងលើ ករណីនេះប្រធានគណៈកម្មការការិយាល័យបោះឆ្នោតអាចពន្យារការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះជាបណ្ដោះអាសន្ន ហូតដល់ពេលដែលនីតិវិធីខាងលើបានបំពេញរួចរាល់ ។

បន្ទាប់ពីបានបិទផ្លាកលេខ ឬសញ្ញាសម្គាល់លើហិបឆ្នោតរួចហើយ ហិបឆ្នោត ទាំងនេះមិនអាចបើកចំហឡើយ លើកលែងតែក្នុងបំណងរាប់សន្លឹកឆ្នោត ដូចមានចែងនៅក្នុងច្បាប់នេះ និងមិនអាចយកចេញពីការិយាល័យបោះឆ្នោត លើកលែងតែការដឹកជញ្ជូនទៅកន្លែងរាប់សន្លឹកឆ្នោត ក្នុងករណីដែលច្បាប់ ឬបទបញ្ជាតម្រូវឲ្យរាប់សន្លឹកឆ្នោតនៅកន្លែងផ្សេង ។

**មាត្រា ១០០.-**

នៅចន្លោះពីម៉ោង ៦:៣០ នាទីព្រឹក ដល់ម៉ោង ៧:០០ នាទីព្រឹក ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យបើកស្រោមសំបុត្រ ដែលមានត្រាសម្ងាត់សម្រាប់បោះនៅលើខ្នងសន្លឹកឆ្នោត រាប់សន្លឹកឆ្នោត និងកត់ត្រាចំនួន ព្រមទាំងលេខរៀងនៅលើគល់បញ្ជីសន្លឹកឆ្នោតតាមបែបបទ ដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១០១.-**

ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវបើកការិយាល័យបោះឆ្នោត នៅម៉ោង ៧:០០ នាទីព្រឹក ។

**មាត្រា ១០២.-**

អ្នកដែលមានសិទ្ធិចូលទៅក្នុងបរិវេណខាងក្នុង និងក្នុងការិយាល័យបោះឆ្នោតបាន លុះត្រាតែជននោះមានឈ្មោះក្នុងបញ្ជីបោះឆ្នោត និងមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែររបស់ខ្លួន ហើយជននោះមិនទាន់បានបោះឆ្នោតនៅឡើយ ។

អ្នកបោះឆ្នោតម្នាក់ៗ ត្រូវបានផ្ដល់សន្លឹកឆ្នោតឲ្យក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលអ្នកបោះឆ្នោតនោះបំពេញបានតាមលក្ខខណ្ឌ ដូចខាងក្រោម ៖

-មានឈ្មោះក្នុងបញ្ជីបោះឆ្នោតនៃការិយាល័យបោះឆ្នោត ដែលសាមីខ្លួនត្រូវបោះឆ្នោត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

-មានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ

មិនទាន់បានបោះឆ្នោតនៅឡើយ ហើយអនុញ្ញាតឲ្យមន្ត្រីបោះឆ្នោតពិនិត្យ មើលម្រាមដៃរបស់បុគ្គលនោះ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវគូសនៅលើសន្លឹកឆ្នោតតែម្នាក់ឯង នៅក្នុងបន្ទប់គូសសន្លឹកឆ្នោតដោយឡែក ហើយដាក់សន្លឹកឆ្នោតដែលបានគូសរួចនោះទៅក្នុងហិបឆ្នោតនៅក្នុងការិយាល័យបោះឆ្នោត បន្ទាប់មកត្រូវអនុញ្ញាតឲ្យមន្ត្រីការិយាល័យបោះឆ្នោតជ្រលក់ទឹកខ្មៅលុបមិនជ្រះ ទៅតាមនីតិវិធីដែលបានកំណត់ ។

របៀបគូសសន្លឹកឆ្នោត និងដាក់សន្លឹកឆ្នោតចូលក្នុងហិបឆ្នោត ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតាក់តែងបទបញ្ជា ដើម្បីអនុវត្តជាក់ស្តែងនូវមាត្រានេះ និងកំណត់អំពីការគ្រប់គ្រងនីតិវិធីបោះឆ្នោត នៅក្នុងការិយាល័យបោះឆ្នោត ។

**មាត្រា ១០៣.-**

សមាជិកនៃគណៈកម្មការការិយាល័យបោះឆ្នោតត្រូវបានអញ្ជើញឲ្យបោះឆ្នោតមុនគេ បន្ទាប់មកភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ដែលមានឈ្មោះក្នុងបញ្ជីបោះឆ្នោតក្នុងការិយាល័យបោះឆ្នោតនោះ ។

**មាត្រា ១០៤.-**

អ្នកបោះឆ្នោតដែលបានធ្វើឲ្យខូចសន្លឹកឆ្នោតដោយអចេតនា ត្រូវប្រគល់សន្លឹកឆ្នោតនេះឲ្យមន្ត្រីការិយាល័យបោះឆ្នោត ហើយមន្ត្រីការិយាល័យបោះឆ្នោតត្រូវប្រគល់សន្លឹកឆ្នោតថ្មីមួយជំនួសវិញ ទៅតាមនីតិវិធីដែលកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១០៥.-**

អ្នកបោះឆ្នោតម្នាក់ៗមានសិទ្ធិបោះឆ្នោតតែមួយសន្លឹក និងតែមួយដងគត់ ដោយត្រូវទៅបោះឆ្នោតដោយខ្លួនឯងផ្ទាល់ ។

អ្នកបោះឆ្នោតម្នាក់ៗត្រូវបោះឆ្នោតឲ្យគណបក្សនយោបាយណាមួយដែលខ្លួនពេញចិត្តដោយគូសសញ្ញាយកតែគណបក្សនយោបាយមួយ និងមិនត្រូវកែដូរឬបន្ថែមបន្ថយទេ ។ របៀបបោះឆ្នោតលម្អិតផ្សេងទៀត ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១០៦.-**

ការបោះឆ្នោតជាការសម្ងាត់របស់អ្នកបោះឆ្នោត ។

ការចង់ដឹងអំពីការសម្ងាត់ ឬការបង្ហើបការសម្ងាត់តាមរូបភាពណាក៏ដោយត្រូវហាមឃាត់ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១០៧.–**

អ្នកបោះឆ្នោតដែលពិការមិនអាចបោះឆ្នោតដោយខ្លួនឯងបាន មានសិទ្ធិជ្រើសរើសអ្នកជំនួយម្នាក់ជានីតិជនទៅជាមួយ ឬមានសិទ្ធិស្នើសុំជំនួយពីប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវតាក់តែងបទបញ្ជាសម្រាប់ការពារសិទ្ធិដល់អ្នកបោះឆ្នោតដែលពិការរាងកាយ ហើយមិនអាចជ្រលក់ទឹកខ្មៅលុបមិនជ្រះបាន ។

**មាត្រា ១០៨.–**

ដើម្បីរក្សារបៀបរៀបរយក្នុងបន្ទប់បោះឆ្នោត ជនម្នាក់ៗត្រូវគោរពតាមបទបញ្ជានៃការបោះ-ឆ្នោតរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១០៩.–**

ប្រជាពលរដ្ឋដែលមានតែឯកសារបញ្ជាក់ពីអត្តសញ្ញាណរបស់ខ្លួន តែពុំមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ពុំអាចបោះឆ្នោតបានឡើយ ។

**មាត្រា ១១០.–**

អាចចូលបានក្នុងការិយាល័យបោះឆ្នោតតែអ្នកត្រូវបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពីគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១១១.–**

មិនអនុញ្ញាតឲ្យជនណាម្នាក់ចូលទៅជ្រៀតជ្រែក ឬជួយអ្នកបោះឆ្នោតក្នុងពេលដែលអ្នកបោះ-ឆ្នោតស្ថិតនៅក្នុងបរិវេណខាងក្នុង ឬក្នុងការិយាល័យបោះឆ្នោតបានឡើយ លើកលែងតែមានការអនុញ្ញាតអនុលោមតាមបទប្បញ្ញត្តិនៃច្បាប់នេះ ។

**មាត្រា ១១២.–**

ហាមដាច់ខាតយកអាវុធ ឬជាតិផ្ទុះគ្រប់ប្រភេទចូលក្នុងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោត និងហាមស្លៀកពាក់ឯកសណ្ឋានជាកងកម្លាំងប្រដាប់អាវុធចូលក្នុងការិយាល័យបោះឆ្នោត លើកលែងតែមានការអនុញ្ញាតពិសេស ពីប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១១៣.–**

មន្ត្រីការិយាល័យបោះឆ្នោត ឬភ្នាក់ងារគណបក្សនយោបាយ មានសិទ្ធិ ប្ដឹងជំទាស់ចំពោះជនណាម្នាក់នៅក្នុងការិយាល័យបោះឆ្នោត ក្នុងករណីដែលជននោះមិនបានបំពេញតាមលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ១០២ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ការប្តឹងជំទាស់ ត្រូវធ្វើទៅកាន់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ។

ក្នុងករណីប្រធានគណៈកម្មការការិយាល័យបោះឆ្នោតពិនិត្យឃើញថា ជននោះមិនបានបំពេញតាមលក្ខខណ្ឌណាមួយ ដូចមានចែងក្នុងមាត្រា ១០២ នៃច្បាប់នេះ ជននោះមិនត្រូវបានអនុញ្ញាតឲ្យបោះឆ្នោតឡើយ ហើយជននោះត្រូវអមដំណើរដោយមន្ត្រីការិយាល័យបោះឆ្នោតឲ្យចេញក្រៅពីការិយាល័យបោះឆ្នោត និងបរិវេណខាងក្នុង ។

ក្នុងករណីប្រធានគណៈកម្មការការិយាល័យបោះឆ្នោតសម្រេចថា ជននោះបានបំពេញលក្ខខណ្ឌតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ១០២ នៃច្បាប់នេះ ជននោះត្រូវបានអនុញ្ញាតឲ្យបោះឆ្នោត ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវកំណត់ដោយបទបញ្ជានូវរបៀបរបបប្តឹងជំទាស់ ការដោះស្រាយ និងការកត់ត្រា អំពីករណីខាងលើនេះ ។

## មាត្រា ១១៤.-

ក្នុងករណីដែលភ្នាក់ងារគណបក្សនយោបាយបានយល់ឃើញថា ការបោះឆ្នោតមិនប្រក្រតី ភ្នាក់ងារគណបក្សនយោបាយនោះ អាចប្តឹងជំទាស់ ឬតវ៉ាមកប្រធានគណៈកម្មការការិយាល័យបោះឆ្នោតបាន ។

របៀបរបបបទប្តឹងជំទាស់ ឬតវ៉ា ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវដោះស្រាយបណ្តឹងជំទាស់ ឬតវ៉ានេះ ។

ការសម្រេចរបស់គណៈកម្មការការិយាល័យបោះឆ្នោត ជាការសម្រេចបានការក្នុងកម្រិតសមត្ថកិច្ចរបស់ខ្លួន ប្រសិនបើការបោះឆ្នោតនោះប្រព្រឹត្តទៅដោយប្រក្រតី ។

ប្រសិនបើអ្នកភ្នាក់ងារគណបក្សនយោបាយនៅតែជំទាស់ ឬតវ៉ាគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចុះបណ្តឹងជំទាស់ ឬតវ៉ានេះ ក្នុងកំណត់ហេតុ ដោយឲ្យអ្នកជំទាស់ ឬតវ៉ានោះចុះហត្ថលេខាជាមួយ ។

## មាត្រា ១១៥.-

បន្ទាប់ពីប្រកាសបិទការបោះឆ្នោត និងក្រោយពីអ្នកបោះឆ្នោតគ្រប់រូបបានបោះឆ្នោតហើយភ្លាម នៅចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវ ៖

-បិទប្រឡោះសម្រាប់ស៊កសន្លឹកឆ្នោតនៃហិបឆ្នោត ដោយមានចុះហត្ថលេខារបស់ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត និងភ្នាក់ងារគណបក្សនយោបាយ លើក្រដាសបិទប្រឡោះ

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

សម្រាប់បោះឆ្នោតនោះ រួចហើយបិទគម្របខាងក្រៅពីលើ និងចាក់សោ ហើយអនុញ្ញាតឲ្យភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ពិនិត្យមើលហិបឆ្នោតនោះ

-ចុះក្នុងកំណត់ហេតុនូវអ្នកដែលបានមកបោះឆ្នោត

-បំពេញ និងចុះហត្ថលេខាលើទម្រង់បែបបទដោយបង្ហាញពីចំនួនសន្លឹកឆ្នោតដែលបានទទួល ដែលបានផ្តល់ឲ្យអ្នកបោះឆ្នោត សន្លឹកឆ្នោតដែលខូច ឬដែលបានដកហូតនៅក្នុងការិយាល័យបោះឆ្នោត

-បំបែកគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើ ចេញពីគល់បញ្ជីសន្លឹកឆ្នោតដែលមិនបានប្រើប្រាស់

-បង្ហាញទម្រង់បែបបទខាងលើដែលបានបំពេញ និងចុះហត្ថលេខារួចហើយ ជូនភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីពិនិត្យ ។

ភ្នាក់ងារគណបក្សនយោបាយអាចចូលរួមចុះហត្ថលេខា ឬផ្តិតមេដៃជាសាក្សី លើកំណត់ហេតុខាងលើនេះ ។

## មាត្រា ១១៦.-

សន្លឹកឆ្នោតត្រូវរាប់នៅការិយាល័យបោះឆ្នោតនីមួយៗក្នុងឃុំ សង្កាត់ ។

ចំពោះការិយាល័យបោះឆ្នោតណា ដែលមិនអាចរាប់សន្លឹកឆ្នោតនៅការិយាល័យបោះឆ្នោតរបស់ខ្លួនបាន ដោយករណីប្រធានសក្តិ ឬអសន្តិសុខ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតនឹងធ្វើការណែនាំដោយឡែក ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវរៀបចំ និងគ្រប់គ្រងការិយាល័យរាប់សន្លឹកឆ្នោតស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងច្បាប់នេះ ។

## មាត្រា ១១៧.-

មន្ត្រីបោះឆ្នោតតាមការិយាល័យបោះឆ្នោតនីមួយៗ ជាអ្នកទទួលខុសត្រូវក្នុងការរាប់សន្លឹកឆ្នោតក្នុងការិយាល័យរបស់ខ្លួន ក្នុងករណីនេះ ការិយាល័យបោះឆ្នោតនឹងក្លាយទៅជាការិយាល័យរាប់សន្លឹកឆ្នោត ។

ក្នុងករណីសន្លឹកឆ្នោត ត្រូវរាប់នៅកន្លែងផ្សេងក្រៅពីការិយាល័យបោះឆ្នោតតាមលក្ខខណ្ឌដូចមានចែងក្នុងកថាខណ្ឌទី ២ នៃមាត្រា ១១៦ នៃច្បាប់នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវចាត់ឲ្យមន្ត្រីការិយាល័យបោះឆ្នោតនោះរាប់សន្លឹកឆ្នោត ឬអាចតែងតាំងមន្ត្រីផ្សេងទៀតឲ្យរាប់សន្លឹកឆ្នោត ក្នុងករណីមន្ត្រីការិយាល័យបោះឆ្នោតនោះ អវត្តមាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## មាត្រា ១១៨.-

ផនគ្រប់រូបនៅក្នុងការិយាល័យរាប់សន្លឹកឆ្នោត និងនៅក្នុងបរិវេណខាងក្នុង ត្រូវស្ថិតក្រោមការគ្រប់គ្រង និងការត្រួតពិនិត្យរបស់ប្រធានការិយាល័យរាប់សន្លឹកឆ្នោត តាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ១១៩.-

គណៈកម្មការការិយាល័យបោះឆ្នោតត្រូវផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោត ដែលមាននៅក្នុងហិបឆ្នោតជាមួយចំនួនអ្នកដែលបានមកបោះឆ្នោត ដែលរាប់ឃើញក្នុងបញ្ជីបោះឆ្នោត ។

ក្នុងករណីដែលសន្លឹកឆ្នោតក្នុងហិបឆ្នោតមានចំនួនខុសគ្នានឹងចំនួនអ្នកបោះឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យរាប់ឡើងវិញ ។

ប្រសិនបើចំនួនខុសគ្នានៅតែមានដដែល ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចុះក្នុងកំណត់ហេតុ ។

មុននឹងចាប់ផ្តើមរាប់សន្លឹកឆ្នោត ប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវហែក ឬកាត់សន្លឹកឆ្នោតដែលមិនបានប្រើប្រាស់ទាំងអស់ ដើម្បីធ្វើមោឃភាពសន្លឹកឆ្នោតដែលនៅសល់មិនបានប្រើ រួចត្រូវដាក់សន្លឹកឆ្នោតមោឃភាព និងគល់បញ្ជីសន្លឹកឆ្នោតដែលបានប្រើទៅក្នុងស្បោងផ្លាស្ទិកតែមួយ រួចបិទឲ្យជិត ។

បន្ទាប់មកប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ត្រូវចាត់ឲ្យរាប់សន្លឹកឆ្នោត ដោយអនុលោមតាមបទបញ្ជា និងនីតិវិធី ។

បន្ទាប់ពីបំពេញបែបបទតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១១៥ មាត្រា ១១៦ និងមាត្រា ១១៧ នៃច្បាប់នេះ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវចាត់ឲ្យបើកហិបឆ្នោត និងចាក់សន្លឹកឆ្នោតទាំងអស់ចេញពីក្នុងហិបឆ្នោតនីមួយៗ រួចហើយ ត្រូវ ៖

-ដាក់វត្ថុដែលមិនមែនជាសន្លឹកឆ្នោត ដាច់ដោយឡែក ប្រសិនបើមាន

-លាសន្លឹកឆ្នោតដែលមានបោះត្រាសម្គាល់ជាផ្លូវការនៅខាងខ្នង ដោយដាក់ ផ្កាប់ចុះក្រោមនៅពំនូកទី ១

-ក្នុងករណីមានសន្លឹកឆ្នោតដែលបានបោះ តែមិនមានបោះត្រាសម្គាល់ជាផ្លូវការនៅខាងខ្នង ត្រូវដាក់ដោយឡែកនៅពំនូកទី ២

-រាប់ចំនួនសន្លឹកឆ្នោតដែលផ្កាប់ចុះក្រោមទាំងពីរពំនូក ហើយកត់ត្រា និងបង្ហាញអំពីចំនួនសន្លឹកឆ្នោតដែលបានរាប់ទាំងពីរពំនូក ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

ROYAUME DU CAMBODGE • LE MINISTERE DU PALAIS ROYAL

ប្រធានការិយាល័យរាប់សន្លឹកឆ្នោត ត្រូវផ្ទៀងផ្ទាត់ចំនួនសន្លឹកឆ្នោតដែលបានរាប់ពីហិបឆ្នោត ជាមួយនឹងចំនួនដែលបានកត់ត្រាក្នុងទម្រង់បែបបទដែលបានបំពេញតាមលក្ខខណ្ឌដែលមានចែងក្នុងមាត្រា ១១៥ នៃច្បាប់នេះ រួចហើយត្រូវបង្ហាញលទ្ធផលនៃការផ្ទៀងផ្ទាត់នេះ ដល់ភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ដើម្បីឲ្យអ្នកទាំងនោះអាចពិនិត្យ តាមដាននិងវាយតម្លៃលទ្ធផលនោះបាន ។

## មាត្រា ១២០.-

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត ត្រូវផ្ទេរសន្លឹកឆ្នោតដែលមានបោះត្រាខាងខ្នងនៅពំនូកទី ១ ដូចមានចែងក្នុងមាត្រា ១១៩ នៃច្បាប់នេះ រួចហើយត្រូវបំបែកសន្លឹកឆ្នោតទាំងនេះជាសន្លឹកឆ្នោតបានការ និងសន្លឹកឆ្នោតមិនបានការ ។

ត្រូវចាត់ទុកជាបានការ សន្លឹកឆ្នោតណាដែលមានគូសសញ្ញាគាំទ្រគណបក្សនយោបាយតែមួយ នៅលើសន្លឹកឆ្នោតដែលគណៈកម្មការការិយាល័យចែកឲ្យ ។

ត្រូវទុកជាមោឃៈសន្លឹកឆ្នោត ៖

១-ដែលពុំមែនជាសន្លឹកឆ្នោតផ្លូវការ ឬ

២-ដែលគ្មានគំនូស ឬមានគំនូសតែគណៈកម្មការការិយាល័យបោះឆ្នោតមិនអាចសន្និដ្ឋានបានថា បោះឆ្នោតឲ្យគណបក្សនយោបាយណាមួយ ឬ

៣-ដែលមានសញ្ញាដែលនាំឲ្យគេស្គាល់អ្នកបោះឆ្នោត ឬ

៤-ដែលមានរហែក ឬខូច ឬ

៥-ដែលគ្មានត្រាសម្គាល់ជាផ្លូវការ ។

សន្លឹកឆ្នោតដែលទុកជាមោឃៈក្នុងចំណុចទី ១ ទី ២ ទី ៣ ទី ៤ ទី ៥ ខាងលើនេះត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

បន្ទាប់មក មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោតត្រូវរាប់សន្លឹកឆ្នោតបានការដែលបានគូសសញ្ញាគាំទ្រគណបក្សនយោបាយនីមួយៗ ។

សន្លឹកឆ្នោតត្រូវរាប់ទៅតាមវិធីមួយដែលអាចមើលឃើញគំនូសនៃការបោះឆ្នោតទាំងអស់ ដោយភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ ។

## មាត្រា ១២១.-

នៅពេលមានការជំទាស់ចំពោះសន្លឹកឆ្នោត ដែលបានរាប់តាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ១២០ នៃច្បាប់នេះ សន្លឹកឆ្នោតដែលមានការជំទាស់នោះ ត្រូវដាក់ដាច់ដោយឡែក ហើយដោះស្រាយទៅតាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១២២ នៃច្បាប់នេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១២២.-**

មន្ត្រីការិយាល័យរាប់សន្លឹកឆ្នោត ត្រូវពិនិត្យមើលគ្រប់សន្លឹកឆ្នោតមិនបានការ និងសន្លឹកឆ្នោតដែលមានការជំទាស់ តាមលក្ខខណ្ឌ ដូចមានចែងក្នុងមាត្រា ១២០ និងមាត្រា ១២១ នៃច្បាប់នេះ ។

ការពិនិត្យសន្លឹកឆ្នោតនេះ ត្រូវធ្វើជាចំហចំពោះមុខភ្នាក់ងារគណបក្សនយោបាយ និងអ្នកសង្កេតការណ៍ និងសុំឲ្យអ្នកទាំងនោះផ្តល់មតិយោបល់ ។

បន្ទាប់ពីបានពិចារណាលើមតិយោបល់ទាំងនេះហើយ ប្រធានការិយាល័យរាប់សន្លឹកឆ្នោតត្រូវសម្រេចបដិសេធចោល និងមិនរាប់សន្លឹកឆ្នោត ដែល ៖

-ពុំមែនជាសន្លឹកឆ្នោតដែលផ្តល់ឲ្យដោយការិយាល័យបោះឆ្នោត

-គ្មានត្រាសម្ងាត់ជាផ្លូវការ

-គូសឲ្យគណបក្សនយោបាយលើសពីមួយ

-គ្មានគំនូស

-មានគំនូស ប៉ុន្តែមិនអាចយកជាការបាន ដោយគំនូសនោះមិនអាចឲ្យមន្ត្រីរាប់សន្លឹកឆ្នោតសម្រេចថា តើគូសឲ្យគណបក្សនយោបាយណាមួយ

-មានសញ្ញាដែលនាំឲ្យគេស្គាល់អ្នកបោះឆ្នោត

-រហែក ឬខូចមិនអាចយកជាការបាន ។

សន្លឹកឆ្នោតដែលបានសម្រេចទទួលយកតាមមាត្រានេះ ត្រូវយកមករាប់បូកជាមួយនឹងសន្លឹកឆ្នោតបានការ ដែលបានរាប់តាមលក្ខខណ្ឌ ដូចមានចែងក្នុងកថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃមាត្រា ១២០ នៃច្បាប់នេះ ទោះបីជាមាន ឬគ្មានការជំទាស់ទៅនឹងការសម្រេចទទួលយកនោះក្តី ។

**មាត្រា ១២៣.-**

បន្ទាប់ពីបានរាប់សន្លឹកឆ្នោតរួចហើយ គណៈកម្មការការិយាល័យបោះឆ្នោតត្រូវធ្វើកំណត់ហេតុអំពីការរាប់សន្លឹកឆ្នោតនេះ រួចផ្ញើជូនគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោតដោយភ្ជាប់ជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន និងឯកសារផ្សេងៗ បិទនៅការិយាល័យបោះឆ្នោត និងចែកជូនភ្នាក់ងារគណបក្សនយោបាយ ដែលមានវត្តមាន ។

សន្លឹកឆ្នោតបានការ ពុំបានការ សន្លឹកឆ្នោតដែលពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ា ឯកសារផ្សេងៗ ត្រូវច្រកដោយឡែកពីគ្នាក្នុងស្រោមសំបុត្រដែលបានចែកឲ្យ ។

កំណត់ហេតុស្តីពីការរាប់សន្លឹកឆ្នោតនេះ ត្រូវចុះហត្ថលេខាដោយប្រធាន និងសមាជិកគណៈ-កម្មការការិយាល័យបោះឆ្នោត ។ ភ្នាក់ងារគណបក្សនយោបាយអាចចុះហត្ថលេខាជាសាក្សីលើកំណត់ហេតុនេះបាន ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

## មាត្រា ១២៤.-

ការបញ្ជូន ការប្រគល់ និងការទទួលកំណត់ហេតុ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធី ។

## មាត្រា ១២៥.-

ភ្នាក់ងារគណបក្សនយោបាយ អ្នកសង្កេតការណ៍ជាតិ និងអន្តរជាតិ អាចចូលរួមជាសាក្សីក្នុងការប្រគល់ ឬការទទួលកំណត់ហេតុបោះឆ្នោត ។

## មាត្រា ១២៦.-

គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវប្រមូលកំណត់ហេតុ និងឯកសារទាំងអស់ពីគ្រប់គណៈកម្មការការិយាល័យបោះឆ្នោត រួចធ្វើកំណត់ហេតុបូកសរុបលទ្ធផលនៃការបោះឆ្នោតក្នុងឃុំ សង្កាត់របស់ខ្លួន ។ កំណត់ហេតុនេះ ត្រូវធ្វើជា ០៤ (បួន) ច្បាប់ ០១ (មួយ) ច្បាប់ផ្ញើជូនគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ០១ (មួយ) ច្បាប់ផ្ញើជូនគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ០១ (មួយ) ច្បាប់ បិទផ្សាយនៅទីស្នាក់ការគណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត និង ០១ (មួយ) ច្បាប់ទៀត ទុកជាឯកសារ ។

ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬពីភាពមិនប្រក្រតីនៅការិយាល័យបោះឆ្នោតណាមួយ គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត ត្រូវបើកការប្រជុំសម្រេចជាសាធារណៈជាបន្ទាន់ ។

ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការឃុំ សង្កាត់ រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬតំណាងមានសិទ្ធិប្តឹងតវ៉ាទៅគណៈកម្មការ រាជធានី ខេត្ត រៀបចំការបោះឆ្នោតជាបន្ទាន់ ។

## មាត្រា ១២៧.-

គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវប្រមូលកំណត់ហេតុទាំងអស់ពីគ្រប់គណៈ-កម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត រួចធ្វើកំណត់ហេតុសរុបពីលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្តរបស់ខ្លួន ។ កំណត់ហេតុនេះត្រូវធ្វើជា ០៣ (បី) ច្បាប់ ០១ (មួយ) ច្បាប់ផ្ញើជូនគណៈកម្មា-ធិការជាតិរៀបចំការបោះឆ្នោត ដោយភ្ជាប់ទៅជាមួយនូវបញ្ជីបោះឆ្នោត សន្លឹកឆ្នោតបានការ សន្លឹកឆ្នោតពុំបានការ សន្លឹកឆ្នោតពុំបានប្រើប្រាស់ ពាក្យបណ្តឹងជំទាស់ ឬតវ៉ាប្រសិនបើមាន ព្រមទាំងឯកសារផ្សេងៗទៀត ០១ (មួយ) ច្បាប់ បិទនៅទីស្នាក់ការគណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត និង ០១ (មួយ) ច្បាប់ទៀត ទុកជាឯកសារ ។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL • ព្រះរាជាណាចក្រកម្ពុជា

## មាត្រា ១២៨.-

ក្នុងករណីមានបណ្តឹងតវ៉ាអំពីលទ្ធផលនៃការបោះឆ្នោត ឬអំពីភាពមិនប្រក្រតីធ្ងន់ធ្ងរណាមួយ គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត ត្រូវធ្វើសវនាការជាសាធារណៈ ដើម្បីសម្រេចអំពីបណ្តឹងតវ៉ាទាំងនោះជាបន្ទាន់ រួចហើយត្រូវផ្ញើសេចក្តីសម្រេចរបស់ខ្លួន ភ្ជាប់ជាមួយនឹងកំណត់ហេតុបូកសរុបលទ្ធផលបោះឆ្នោត ជូនទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីអ្នកប្តឹងតវ៉ាពុំពេញចិត្តនឹងសេចក្តីសម្រេចរបស់គណៈកម្មការរាជធានី ខេត្ត រៀបចំការបោះឆ្នោត អ្នកប្តឹងតវ៉ា ឬតំណាងត្រូវធ្វើការប្តឹងតវ៉ាទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាបន្ទាន់ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការពិនិត្យ និងសម្រេចថា លទ្ធផលនៃការបោះឆ្នោតនេះជាបានការ ឬឲ្យបោះឆ្នោតសាជាថ្មី ។

ការបោះឆ្នោតសាជាថ្មីត្រូវធ្វើឡើងរយៈពេល ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

## មាត្រា ១២៩.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រមូលលទ្ធផលទាំងអស់មកពិនិត្យ ហើយធ្វើការសម្រេចលើលទ្ធផលបោះឆ្នោត ។

បើភាពមិនប្រក្រតីមិនធ្ងន់ធ្ងរទេ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវប្រកាសទទួលស្គាល់លទ្ធផលនៃការបោះឆ្នោត ។

ប្រសិនបើភាពមិនប្រក្រតីមានកម្រិតធ្ងន់ធ្ងរ ធ្វើឲ្យប៉ះពាល់ដល់លទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយជូនព័ត៌មានដល់គណបក្សនយោបាយ ។ ក្នុងករណីនេះ ការបោះឆ្នោត សាជាថ្មី នៅការិយាល័យនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ត្រូវធ្វើ ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

## មាត្រា ១៣០.-

ក្រោយពីការត្រួតពិនិត្យ និងសម្រេចលើលទ្ធផលនៃការបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយលទ្ធផលបណ្តោះអាសន្ននៃការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។

លទ្ធផលបណ្តោះអាសន្ននេះ ត្រូវធ្វើ ០១ (មួយ) ច្បាប់ថ្វាយព្រះមហាក្សត្រ និង ០១ (មួយ) ច្បាប់ផ្ញើជូនក្រុមប្រឹក្សាធម្មនុញ្ញ ។ គណបក្សនយោបាយដែលចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានសិទ្ធិសុំសេចក្តីចម្លងលទ្ធផលបណ្តោះអាសន្ននេះបាន ។



**មាត្រា ១៣១.-**

បន្ទាប់ពីការប្រកាសលទ្ធផលបោះឆ្នោតបណ្តោះអាសន្នក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ គ្រប់គណបក្សនយោបាយដែលបានឈរឈ្មោះបោះឆ្នោត អាចប្តឹងតវ៉ាអំពីលទ្ធផលមួយផ្នែក ឬលទ្ធផលទាំងអស់នៃការបោះឆ្នោតទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬទៅក្រុមប្រឹក្សាធម្មនុញ្ញ ដោយផ្ទាល់ក៏បាន ដោយបញ្ជាក់ពីភាពមិនប្រក្រតីនៃគណៈកម្មការ ឬសមាជិកគណៈកម្មការដែលធ្វើខុសពីកាលបរិច្ឆេទ ដែលធ្វើខុសពីកន្លែងដែលមានការប្រព្រឹត្តខុស ពីឈ្មោះ និងអាសយដ្ឋាននៃសាក្សី ព្រមទាំងឯកសារ ឬភស្តុតាងដទៃទៀត ។

**មាត្រា ១៣២.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវសម្រេចលើបណ្តឹងតវ៉ា ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីទទួលបានពាក្យបណ្តឹង ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតសម្រេចថា បណ្តឹងតវ៉ាពុំអាចទទួលបាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធមួយច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ ។

-ផ្តល់ព័ត៌មានទៅអ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយថា អនុលោមតាមមាត្រា ១៣៤ នៃច្បាប់នេះ សាមីខ្លួន ឬគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីទទួលបានលិខិតជូនដំណឹងបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ។

**មាត្រា ១៣៣.-**

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតយល់ថា បណ្តឹងតវ៉ាមានទឡ្ហីករណ៍សមហេតុ សមផល គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវបើកសវនាការជាសាធារណៈដើម្បីសម្រេច។ ក្នុងករណីនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយកាលបរិច្ឆេទ និងទីកន្លែងនៃសវនាការ ផ្តល់ព័ត៌មានទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងជូនព័ត៌មានទៅក្រុមប្រឹក្សាធម្មនុញ្ញ ។

អ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយ និងសមាជិកគណៈកម្មការរៀបចំការបោះឆ្នោត ឬ/និងគណៈកម្មការរៀបចំការបោះឆ្នោតដែលពាក់ព័ន្ធ ត្រូវមានវត្តមាននៅក្នុងសវនាការនេះ ។

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត យល់ព្រមតាមពាក្យបណ្តឹង គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-បដិសេធលទ្ធផលនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយរៀបចំឲ្យមានការបោះឆ្នោតសាជាថ្មីនៅកន្លែងនោះ ឬកន្លែងទាំងនោះ ក្នុងរយៈពេល ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

-បំពេញបែបបទនៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការយល់ព្រម ។

-ផ្តល់សេចក្តីចម្លងសេចក្តីយល់ព្រម ០១ (មួយ) ច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ ។

-ផ្តល់សេចក្តីចម្លងសេចក្តីយល់ព្រម ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ជាឯកសារ ។

ប្រសិនបើគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ពុំយល់ព្រមតាមបណ្តឹងតវ៉ា គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយ ។

-ផ្តល់ព័ត៌មានដល់អ្នកប្តឹងតវ៉ា ឬ/និងគណបក្សនយោបាយថា អនុលោមតាមមាត្រា ១៣៤ នៃច្បាប់នេះ សាមីខ្លួន ឬគណបក្សនយោបាយមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃទទួលបានលិខិតជូនដំណឹងបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ទៅក្រុមប្រឹក្សាធម្មនុញ្ញ ដើម្បីជាព័ត៌មាន និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

**មាត្រា ១៣៤.-**

ជនណា ឬ/និងគណបក្សនយោបាយណាដែលបណ្តឹងតវ៉ារបស់ខ្លួនត្រូវបានបដិសេធដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជននោះ ឬ/និងគណបក្សនយោបាយនោះមានសិទ្ធិប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងរយៈពេល ៧២ (ចិតសិបពីរ) ម៉ោងយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលលិខិតជូនដំណឹងពីការបដិសេធ ។

ក្រុមប្រឹក្សាធម្មនុញ្ញត្រូវបើកសវនាការជាសាធារណៈ សម្រេចលើបណ្តឹងតវ៉ានេះក្នុងរយៈពេល ពី ១០ (ដប់) ថ្ងៃទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីបានទទួលពាក្យបណ្តឹង ។

ការសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចចុងក្រោយ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញសម្រេចថា បណ្តឹងតវ៉ាពុំអាចទទួលបាន ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធដែលបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធ ០១ (មួយ) ច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-ផ្សព្វផ្សាយសេចក្តីសម្រេច និងទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

ប្រសិនបើក្រុមប្រឹក្សាធម្មនុញ្ញយល់ថា បណ្តឹងតវ៉ាមានទទ្បីករណ៍សមហេតុ សមផល ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបើកសវនាការជាសាធារណៈ ដើម្បីពិនិត្យ និងសម្រេចក្នុងរយៈពេល ១០ (ដប់) ថ្ងៃទៅ ២០ (ម្ភៃ) ថ្ងៃយ៉ាងយូរ បន្ទាប់ពីថ្ងៃបានទទួលពាក្យបណ្តឹង ។

ក.ក្នុងករណីក្រុមប្រឹក្សាធម្មនុញ្ញយល់ព្រមតាមពាក្យបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ ៖

-បំពេញបែបបទនៃការយល់ព្រមដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការយល់ព្រម ។

-ផ្តល់សេចក្តីសម្រេចនៃការយល់ព្រម ០១ (មួយ) ច្បាប់ទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ ។

-ចេញសេចក្តីសម្រេចឲ្យគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតបដិសេធលទ្ធផលនៃការបោះឆ្នោតនៅការិយាល័យបោះឆ្នោតនោះ ឬនៅការិយាល័យបោះឆ្នោតទាំងនោះ ហើយឲ្យរៀបចំការបោះឆ្នោតសាជាថ្មីនៅកន្លែងនោះ ឬនៅកន្លែងទាំងនោះក្នុងរយៈពេល ០៨ (ប្រាំបី) ថ្ងៃយ៉ាងយូរ បន្ទាប់ពីការសម្រេចនេះ ។

-ផ្សព្វផ្សាយសេចក្តីសម្រេច និងរក្សាទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

ខ.ក្នុងករណីដែលក្រុមប្រឹក្សាធម្មនុញ្ញពុំយល់ព្រមតាមបណ្តឹងតវ៉ា ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវ ៖

-បំពេញបែបបទនៃការបដិសេធ ដោយបញ្ជាក់ពីមូលហេតុ និងកាលបរិច្ឆេទនៃការបដិសេធ ។

-ផ្តល់សេចក្តីចម្លងនៃសេចក្តីបដិសេធទៅអ្នកប្តឹងតវ៉ា ឬ/និងទៅគណបក្សនយោបាយ និងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

-ផ្សព្វផ្សាយសេចក្តីបដិសេធ និងទុក ០១ (មួយ) ច្បាប់ ជាឯកសារ ។

**មាត្រា ១៣៥.–**

ក.ក្រោយពីបណ្តឹងតវ៉ាត្រូវបានសម្រេចជាស្ថាពរ និងក្រោយពីបានទទួលលទ្ធផលនៃការបោះ-ឆ្នោតទាំងអស់ រួមទាំងលទ្ធផលនៃការបោះឆ្នោតដែលត្រូវធ្វើសាជាថ្មី ប្រសិនបើមាន គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវផ្សព្វផ្សាយជាផ្លូវការលទ្ធផលនៃការបោះឆ្នោត ហើយកំណត់ចំនួនអាសនៈសម្រាប់គណបក្សនយោបាយនីមួយៗតាមមណ្ឌលនីមួយៗ ដោយគិតតាមចំនួនសន្លឹកឆ្នោតបានការ ។

ការបែងចែកអាសនៈតាមរាជធានី ខេត្ត ត្រូវធ្វើតាមរូបមន្តមធ្យមភាគខ្ពស់បំផុតដោយផ្អែកលើចំនួនអាសនៈក្នុងរាជធានី ខេត្ត និងលទ្ធផលនៃការបោះឆ្នោតក្នុងរាជធានី ខេត្ត តាមជំហានទាំងឡាយដូចខាងក្រោម ៖

**ជំហានទី ១** : កំណត់ចំនួនកូតាដែលតម្រូវឲ្យគណបក្សនយោបាយណាមួយទទួលអាសនៈ ០១ (មួយ) ដោយយកចំនួនសន្លឹកឆ្នោតបានការសរុបនៅក្នុង រាជធានី ខេត្ត មកចែកនឹងចំនួនអាសនៈសរុបក្នុងរាជធានី ឬខេត្ត តាមរូបមន្តដូចខាងក្រោមនេះ និងត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់រាជធានី ខេត្តនីមួយៗ ៖

$$ក_{ត} = \frac{ស_{ស}}{អ_{ស}}$$

ក្នុងនោះ ៖

-$ក_{ត}$ : តាងឲ្យកូតាជាផលចែក ដោយមិនគិតសំណល់ចែក ។

-$ស_{ស}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យគណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុង រាជធានី ខេត្ត ។

-$អ_{ស}$ : តាងឲ្យចំនួនអាសនៈសរុបតាមមណ្ឌលរាជធានី ខេត្ត ។

**ជំហានទី ២** : កំណត់ចំនួនអាសនៈជាបឋមដែលគណបក្សនយោបាយនីមួយៗបានទទួលនៅក្នុងរាជធានី ខេត្ត ។

រូបមន្តដូចខាងក្រោមត្រូវអនុវត្តដាច់ដោយឡែកពីគ្នា សម្រាប់គណបក្សនយោបាយនីមួយៗដែលបានចូលរួមនៅក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ៖

$$អ_{ទ} = \frac{ស_{ប}}{ក_{ត}}$$

ក្នុងនោះ ៖

-$អ_{ទ}$: ជាផលចែកដោយមិនគិតពីសំណល់ចែក តាងឲ្យចំនួនអាសនៈដែលគណបក្សនយោបាយនីមួយៗ មានសិទ្ធិបានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ណាមួយក្នុងជំហានទី ៣ ។

-$ស_{ប}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឲ្យគណបក្សនយោបាយណាមួយនៅក្នុងរាជធានី ខេត្ត ។

-$ក_{ត}$: តាងឲ្យកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

បន្ទាប់ពីគណនា គ្រប់គណបក្សនយោបាយទាំងអស់ដែលបានចូលរួមក្នុងការបោះឆ្នោតក្នុងរាជធានី ខេត្ត ក្នុងជំហានទី២ ប្រសិនបើគ្មានអាសនៈនៅសល់ ដើម្បីបែងចែកបន្តទៀតនោះ ចំនួនអាសនៈត្រូវសម្រេចកំណត់យកតែម្តង ។

ក្នុងករណីមានអាសនៈនៅសល់ត្រូវបន្តបែងចែក បន្ទាប់ពីធ្វើការគណនាសម្រាប់គណបក្សនយោបាយទាំងអស់ ដែលបានចូលរួមក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត អាសនៈដែលនៅសល់ទាំងនេះត្រូវកំណត់ទៅតាមរបៀបដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣** : អាសនៈដែលនៅសល់ ត្រូវបែងចែកឲ្យគណបក្សនយោបាយនីមួយៗមានសិទ្ធិបានទទួលនៅក្នុងរាជធានី ខេត្ត ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត ។ រូបមន្តដូចខាងក្រោម ត្រូវអនុវត្តដាច់ដោយឡែកពីគ្នាសម្រាប់គណបក្សនយោបាយនីមួយៗ ដែលបានចូលរួមក្នុងការបោះឆ្នោតតាម រាជធានី ខេត្ត ៖

$$ម_{ធ} = \frac{ស_{ប}}{អ_{ទ} + ១}$$

ក្នុងនោះ ៖

-$ម_{ធ}$ : តាងឲ្យមធ្យមភាគខ្ពស់បំផុត ។

-$ស_{ប}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការ ដែលបានបោះឲ្យគណបក្សនយោបាយមួយ ។

-$អ_{ទ}$ : តាងឲ្យចំនួនអាសនៈដែលបានបែងចែកឲ្យទៅគណបក្សនយោបាយមួយ ។

ក្នុងករណីដែលនៅសល់អាសនៈចំនួន ០១ (មួយ) ដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្ត ក្នុងជំហានទី ៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះត្រូវបែងចែកទៅឲ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាង ០១ (មួយ) ដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុងជំហានទី៣ ហើយអាសនៈចំនួន ០១ (មួយ) ត្រូវបែងចែកទៅឲ្យគណបក្សនយោបាយណាដែលមធ្យមភាគខ្ពស់បំផុត ។ បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ $អ_{ទ}$ ចំនួន ០១ (មួយ) ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួន ០១ (មួយ) ក្នុងការអនុវត្តរូបមន្តលើកទីមួយ។ ដូច្នេះចំនួនអាសនៈចំនួន ០១ (មួយ) ត្រូវផ្តល់ឲ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈ ត្រូវ

បែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈជាបន្តបន្ទាប់ រហូតដល់អស់អាសនៈដែលនៅសល់ ។

ខ.ការប្រកាសបេក្ខជនជាប់ឆ្នោតជាតំណាងរាស្ត្រ ត្រូវអនុលោមទៅតាមបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត និងអនុវត្តតាមលំដាប់លេខរៀង ដូចមានចែងក្នុងមាត្រា ២៨ នៃច្បាប់នេះ ។

គ.ប្រសិនបើក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតមានអ្នកជាប់ឆ្នោតទទួលមរណភាព ឬលាលែង ឬប្រាសចាកពីបេក្ខភាពតំណាងរាស្ត្រ បេក្ខជនដែលមានឈ្មោះបន្ទាប់នៅក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនោះ ត្រូវបានប្រកាសថា ជាប់ឆ្នោតជាតំណាងរាស្ត្ររបស់សាមីគណបក្សនយោបាយ ។

ឃ.ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ដោយមូលហេតុដូចមានចែងក្នុងចំណុច គ នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវស្នើជាលាយលក្ខណ៍អក្សរទៅសាមីគណបក្សនោះ ឱ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេល ១៤ (ដប់បួន) ថ្ងៃ ក្រោយពីបានទទួលសំណើ ។

បែបបទនៃការទទួលពិនិត្យ និងអនុម័តបេក្ខជនដែលស្នើបន្ថែមនេះត្រូវអនុវត្តតាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ២៣ មាត្រា ២៤ មាត្រា ២៥ មាត្រា ២៦ មាត្រា ២៨ មាត្រា ៣២ មាត្រា ៣៣ មាត្រា ៣៤ មាត្រា ៣៥ និងមាត្រា ៣៦ នៃច្បាប់នេះ ។

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ឬមិនបានកែលម្អការខ្វះខាតដែលធ្វើឱ្យគណបក្សនយោបាយនោះមិនអាចបំពេញអាសនៈដែលនៅទំនេរបាន ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះបោះបង់ចោលអាសនៈឱ្យនៅទំនេរ ។

ង.ក្នុងករណីគណបក្សនយោបាយណាមួយបានទទួលអាសនៈ ០១ (មួយ) ឬច្រើននៅក្នុងរដ្ឋសភា ប៉ុន្តែគណបក្សនយោបាយនោះបានប្រកាសបោះបង់ចោលអាសនៈរបស់ខ្លួន ឬត្រូវបានលុបឈ្មោះចេញពីបញ្ជីឈ្មោះគណបក្សនយោបាយ តាមច្បាប់ស្តីពីគណបក្សនយោបាយ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

ក្នុងករណីខាងលើនេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ០៧ (ប្រាំពីរ) ថ្ងៃ ទៅឱ្យគណបក្សនយោបាយផ្សេងដែលទទួលបានអាសនៈក្នុងរាជធានី ខេត្តជាមួយ តាមជំហានទាំងឡាយដូចខាងក្រោម ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបោះបង់អាសនៈ ៖

**ជំហានទី ១** : កំណត់កូតាដែលតម្រូវឱ្យគណបក្សនយោបាយបានទទួល ០១ (មួយ) អាសនៈ តាមរូបមន្ត ខាងក្រោម ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

$$\text{ក'}_{\text{ត}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}}$$

ក្នុងនោះ ៖

-$\text{ក'}_{\text{ត}}$ : តាងឲ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក ។

-$\text{ស'}_{\text{ស}}$ : តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុប បោះឲ្យគណបក្សនយោបាយទាំងអស់ដែលទទួលអាសនៈក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឲ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងរាជធានី ខេត្ត ។

-$\text{អ'}_{\text{ប}}$ : តាងឲ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងរាជធានី ខេត្ត ។

**ជំហានទី ២** : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួលតាមរូបមន្តខាងក្រោម ៖

$$\text{អ'}_{\text{ទ}} = \frac{\text{ស}_{\text{ប}}}{\text{ក'}_{\text{ត}}}$$

ក្នុងនោះ ៖

-$\text{អ'}_{\text{ទ}}$: តាងឲ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត បានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី ៣ ។

-$\text{ស}_{\text{ប}}$: តាងឲ្យសន្លឹកឆ្នោតបានការសរុប បោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-$\text{ក'}_{\text{ត}}$: តាងឲ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីបានគណនាក្នុងជំហានទី ២ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងរាជធានី ខេត្ត លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងរាជធានី ខេត្ត ក្នុងករណីគ្មាននៅសល់អាសនៈដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេចត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី ៣ ។

**ជំហានទី ៣** : អាសនៈដែលនៅសល់ ត្រូវបែងចែកដោយកំណត់យកមធ្យមភាគខ្ពស់បំផុតតាមរូបមន្តខាងក្រោម ៖

$$\text{ម'}_{\text{ធ}} = \frac{\text{ស}_{\text{ប}}}{\text{អ'}_{\text{ទ}}\text{'1}}$$

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងនោះ ៖

-$ម'_{ធ}$ : តាងឲ្យមធ្យមភាគខ្ពស់បំផុត ។

-$ស_{ប}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-$អ'_{ម}$: តាងឲ្យចំនួនអាសនៈ ដែលបានបែងចែកឲ្យទៅគណបក្សនយោបាយមួយ ។

វិធីសាស្ត្រដូចមានចែងក្នុងកថាខណ្ឌទី ៩ និងកថាខណ្ឌទី ១០ នៃចំណុច ក នៃមាត្រានេះ ត្រូវអនុវត្តចំពោះការគណនាក្នុងជំហានទី ៣ និងការគណនាជាបន្តបន្ទាប់ទៀត ។

ច.ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នា ដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឲ្យគណបក្សណាមួយបាន អាសនៈនោះត្រូវផ្តល់ជូនទៅគណបក្សនយោបាយដែលទទួលបានចំនួនសន្លឹកឆ្នោតបានការខ្ពស់ជាងគេ ។ ក្នុងករណីចំនួនសន្លឹកឆ្នោតបានការរបស់គណបក្សនយោបាយស្មើគ្នាទៀតនោះ អាសនៈដែលនៅសល់នោះត្រូវបែងចែកទៅឲ្យគណបក្សនយោបាយតាមការចាប់ឆ្នោត ដែលកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ឆ.ក្នុងករណីគណបក្សនយោបាយណាមួយទទួលបានអាសនៈបន្ថែមមួយ ឬច្រើន ប៉ុន្តែបញ្ជីបេក្ខជនរបស់ខ្លួនមានបេក្ខជនតិចជាងអាសនៈនោះ ត្រូវអនុវត្តតាមនីតិវិធី ដូចមានចែងក្នុងចំណុច ឃ នៃមាត្រានេះ ។

ជ.ផ្អែកតាមលទ្ធផលនៃការបោះឆ្នោតដូចមានចែងក្នុងចំណុច ក នៃមាត្រានេះ គណកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចធ្វើការប្រកាសលទ្ធផលនៃការបោះឆ្នោតតាមមណ្ឌលនីមួយៗ ជាបន្តបន្ទាប់ ។

ឈ.មុនពេលប្រកាសលទ្ធផលនៃការបោះឆ្នោតជាផ្លូវការ គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ត្រូវធ្វើសេចក្តីរាយការណ៍ជូនគ្រប់តំណាងគណបក្សនយោបាយ ដែលចូលរួមបោះឆ្នោត នូវចំនួនសន្លឹកឆ្នោតសរុបដែលបានបោះពុម្ព ចំនួនសន្លឹកឆ្នោតដែលបានប្រើប្រាស់ និងចំនួនសន្លឹកឆ្នោតដែលនៅសល់ ។

**មាត្រា ១៣៦.–**

ការរាប់ចំនួនថ្ងៃតវ៉ា និងការសម្រេចលើបណ្តឹងតវ៉ា ដូចមានចែងក្នុងជំពូកទី ៤ ជំពូកទី ៦ និងជំពូកទី ៨ នៃច្បាប់នេះ ពុំត្រូវបានរាប់បញ្ចូលថ្ងៃបុណ្យជាផ្លូវការ ។

ROYAUME DU CAMBODGE LE MINISTRE DU PALAIS ROYAL

**មាត្រា ១៣៧.-**

ក្នុងអំឡុងពេលបោះឆ្នោត ពេលរាប់សន្លឹកឆ្នោត និងការប្រកាសលទ្ធផលនៃការបោះឆ្នោត អង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិ ដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ឬជនបរទេស ត្រូវប្រកាន់ជំហរអព្យាក្រឹតឥតលម្អៀង ស្របតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងមាត្រា ៨៤ នៃច្បាប់នេះ ។

បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ មិនត្រូវរាំងដល់ការប្រើប្រាស់សេរីភាពក្នុងការបញ្ចេញមតិដែលស្របតាមច្បាប់ជាធរមាន ។

## ជំពូកទី ៩
## ការបាត់បង់អាសនៈនៃរដ្ឋសភា និងការជ្រើសតាំងជំនួស

**មាត្រា ១៣៨.-**

បន្ទាប់ពីដំណើរការនៃការបោះឆ្នោត បានប្រព្រឹត្តទៅដោយសេរី ត្រឹមត្រូវ និងយុត្តិធម៌ ស្របតាមរដ្ឋធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត និងច្បាប់ស្តីពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ហើយបន្ទាប់ពីការប្រកាសលទ្ធផលផ្លូវការនៃការបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតរួច គណបក្សនយោបាយណាមួយដែលទទួលបានអាសនៈមួយ ឬច្រើនក្នុងរដ្ឋសភា ត្រូវចាត់ទុកថា បានបោះបង់ចោលអាសនៈរបស់ខ្លួន ក្នុងករណីណាមួយ ដូចខាងក្រោម ៖

-គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមសម័យប្រជុំដំបូង តាមការកោះប្រជុំរបស់ព្រះមហាក្សត្រ ។

-គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមចូលរួមប្រជុំរដ្ឋសភាសម្រាប់ការប្រកាសសុពលភាពនៃអាណត្តិរបស់សមាជិកនីមួយៗ ។

-គណបក្សនយោបាយនោះ ធ្វើពហិការមិនព្រមធ្វើសច្ចាប្រណិធានចូលកាន់តំណែង ។

ក្នុងករណីខាងលើនេះ បញ្ជីបេក្ខជន និងបេក្ខជននៃគណបក្សនយោបាយនោះដែលបានប្រកាសថា ជាប់ឆ្នោតរួចហើយ មិនមានសុពលភាព និងមិនមានគុណសម្បត្តិតទៅទៀតបានឡើយ ។

រដ្ឋសភាត្រូវជូនដំណឹងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតជាបន្ទាន់ ឬក្នុងរយៈពេលយ៉ាងយូរ ២៤ (ម្ភៃបួន) ម៉ោង។ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវធ្វើការបែងចែកអាសនៈដែលនៅទំនេរនោះ ក្នុងរយៈពេលយ៉ាងយូរ ៧២ (ចិតសិបពីរ) ម៉ោង បន្ទាប់ពីបានទទួលលិខិតជូនដំណឹងពីរដ្ឋសភា ទៅឲ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

ក្នុងរាជធានី ខេត្ត ជាមួយគ្នា ដោយមិនគិតបញ្ចូលគណបក្សនយោបាយដែលបាត់បង់អាសនៈ ដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើ តាមជំហានទាំងឡាយ ដូចខាងក្រោម ៖

**ជំហានទី ១** : កំណត់កូតាដែលតម្រូវឲ្យគណបក្សនយោបាយបានទទួល ០១ (មួយ) អាសនៈ តាមរូបមន្តខាងក្រោម ៖

$$\text{ក'}_{\text{ត}} = \frac{\text{ស'}_{\text{ស}}}{\text{អ'}_{\text{ប}}}$$

ក្នុងនោះ៖

-ក'ត : តាងឲ្យកូតាជាផលចែកដោយមិនគិតពីសំណល់ចែក ។

-ស'ស:តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបបោះឲ្យគណបក្សនយោបាយផ្សេងដែលបានចុះបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោត ក្នុងការបោះឆ្នោតនៅក្នុងរាជធានី ខេត្ត ដកចេញនូវសន្លឹកឆ្នោតបានការដែលបានបោះឲ្យគណបក្សនយោបាយដែលបោះបង់អាសនៈនៅក្នុងរាជធានី ខេត្ត ។

-អ'ប:តាងឲ្យអាសនៈដែលបានបោះបង់ចោលនៅក្នុងរាជធានី ខេត្ត ។

**ជំហានទី ២** : កំណត់ចំនួនអាសនៈជាបឋម ដែលគណបក្សនយោបាយនីមួយៗបានទទួល តាមរូបមន្តខាងក្រោម ៖

$$\text{អ'}_{\text{ម}} = \frac{\text{ស}_{\text{ប}}}{\text{ក'}_{\text{ត}}}$$

ក្នុងនោះ ៖

-អ'ម: តាងឲ្យចំនួនអាសនៈដែលគណបក្សនយោបាយមួយក្នុង រាជធានី ខេត្ត បានទទួលមុនពេលធ្វើប្រមាណវិធីចាំបាច់ក្នុងជំហានទី ៣ ។

-សប: តាងឲ្យសន្លឹកឆ្នោតបានការសរុប បោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-ក'ត: តាងឲ្យចំនួនកូតាដែលបានកំណត់ក្នុងជំហានទី ១ ។

បន្ទាប់ពីបានគណនាក្នុងជំហានទី ២ គ្រប់គណបក្សនយោបាយដែលទទួលបានអាសនៈក្នុងរាជធានី ខេត្ត លើកលែងតែគណបក្សនយោបាយដែលបោះបង់អាសនៈក្នុងរាជធានី ខេត្ត ក្នុងករណីគ្មាននៅសល់អាសនៈដើម្បីបែងចែកបន្តទៀត ចំនួនអាសនៈសម្រេច ត្រូវកំណត់យកតែម្តង ។

ក្នុងករណីគណនាក្នុងជំហានទី ២ រួចហើយ ប៉ុន្តែមានអាសនៈនៅសល់ដែលត្រូវបន្តបែងចែកតទៅទៀត អាសនៈដែលនៅសល់នោះ ត្រូវបែងចែកតាមរូបមន្តដែលបានកំណត់ក្នុងជំហានទី ៣ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ជំហានទី ៣ : អាសនៈដែលនៅសល់ត្រូវបែងចែក ដោយកំណត់យកមធ្យមភាគខ្ពស់បំផុត តាមរូបមន្តខាងក្រោម ៖

$$ម'_{ធ} = \frac{ស_{ប}}{អ'_{ខ} + 1}$$

ក្នុងនោះ ៖

-$ម'_{ធ}$ : តាងឲ្យមធ្យមភាគខ្ពស់បំផុត។

-$ស_{ប}$: តាងឲ្យចំនួនសន្លឹកឆ្នោតបានការសរុបដែលបានបោះឲ្យគណបក្សនយោបាយមួយក្នុងរាជធានី ខេត្ត ។

-$អ'_{ខ}$: តាងឲ្យចំនួនអាសនៈ ដែលបានបែងចែកឲ្យទៅគណបក្សនយោបាយមួយ ។

ក្នុងករណីដែលនៅសល់អាសនៈចំនួន ០១ (មួយ) ដែលត្រូវបែងចែក បន្ទាប់ពីបានគណនាតាមរូបមន្ត ក្នុងជំហានទី ៣ សម្រាប់គណបក្សនយោបាយដែលមានលក្ខណសម្បត្តិទាំងអស់ អាសនៈនោះ ត្រូវបែងចែកទៅឲ្យគណបក្សនយោបាយដែលមានមធ្យមភាគខ្ពស់បំផុត ។

ក្នុងករណីដែលនៅសល់អាសនៈច្រើនជាង ០១ (មួយ) ដែលត្រូវបែងចែក ត្រូវអនុវត្តតាមរូបមន្តក្នុង ជំហានទី ៣ ហើយអាសនៈចំនួន ០១ (មួយ) ត្រូវបែងចែកទៅឲ្យគណបក្សនយោបាយណាដែលមធ្យមភាគខ្ពស់បំផុត ។

បន្ទាប់មកត្រូវអនុវត្តរូបមន្តនេះម្តងទៀត ដោយបង្កើនតម្លៃ $អ_{ខ}$ ចំនួន ០១ (មួយ) ចំពោះគណបក្សនយោបាយដែលបានទទួលអាសនៈចំនួន ០១ (មួយ) ក្នុងការអនុវត្តរូបមន្តលើកទីមួយ ។ ដូច្នេះចំនួនអាសនៈចំនួន ០១ (មួយ) ត្រូវផ្តល់ឲ្យគណបក្សនយោបាយ ដែលមានមធ្យមភាគខ្ពស់បំផុត ក្នុងការអនុវត្តរូបមន្តលើកទីពីរ ។ ក្នុងករណីនៅសល់អាសនៈ ត្រូវបែងចែកបន្តទៀតនោះ ការគណនាត្រូវធ្វើតាមរបៀបដដែល ដោយបែងចែកអាសនៈម្តងមួយអាសនៈជាបន្តបន្ទាប់រហូតដល់អស់អាសនៈដែលនៅសល់ ។

ក្នុងករណីគណនាតាមរូបមន្តខាងលើ មានគណបក្សនយោបាយពីរ ឬច្រើនបានទទួលលទ្ធផលស្មើគ្នាដែលមិនអាចកំណត់បែងចែកអាសនៈដែលនៅសល់ទៅឲ្យគណបក្សណាមួយបាន ត្រូវអនុវត្តតាមចំណុច ច នៃមាត្រា ១៣៥ នៃច្បាប់នេះ ។

ក្នុងករណីបញ្ជីបេក្ខជននៃគណបក្សនយោបាយណាមួយ មានបេក្ខជនមិនគ្រប់គ្រាន់ គណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវស្នើជាលាយលក្ខណ៍អក្សរ ទៅគណបក្សនោះឲ្យបន្ថែមឈ្មោះក្នុងបញ្ជីបេក្ខជនក្នុងរយៈពេលយ៉ាងយូរ ៤៨ (សែសិបប្រាំបី) ម៉ោង ក្រោយពីបានទទួលសំណើ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ក្នុងករណីគណបក្សនយោបាយណាមួយ មិនបានអនុវត្តតាមពេលវេលាខាងលើ ត្រូវចាត់ទុកដូចជាគណបក្សនយោបាយនោះ បោះបង់ចោលអាសនៈឲ្យនៅទំនេរ ។

**មាត្រា ១៣៩.-**

សមាជិករដ្ឋសភាត្រូវបាត់បង់សមាជិកភាពរបស់ខ្លួនទៅតាមករណីណាមួយដូចខាងក្រោម ៖

-សាមីខ្លួនទទួលមរណភាព ។

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈដោយមានលិខិតបញ្ជាក់ពីក្រសួង ស្ថាប័នមានសមត្ថកិច្ច ។

-សាមីខ្លួនសុំលាឈប់ជាលាយលក្ខណ៍អក្សរពីសមាជិករដ្ឋសភា ។

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬបទមជ្ឈិមណាមួយ ។

-សាមីខ្លួនបាត់បង់សមាជិកភាពពីគណបក្សនយោបាយរបស់ខ្លួន ។

កាលបើសមាជិករដ្ឋសភារូបណាមួយត្រូវបាត់បង់សមាជិកភាពមានរយៈពេល ០៦ (ប្រាំមួយ) ខែយ៉ាងតិច មុនចប់នីតិកាល សាមីគណបក្សនយោបាយនោះអាចស្នើជ្រើសតាំងសមាជិកថ្មីជំនួសដោយជ្រើសរើសក្នុងចំណោមបេក្ខជនដែលមានឈ្មោះតាមលំដាប់លេខរៀងក្នុងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតនៃមណ្ឌលបោះឆ្នោតរបស់សាមីខ្លួននោះមកជំនួស ដោយមិនបាច់បោះឆ្នោតឡើងវិញ ។

## ជំពូកទី ១០
## ទោសប្បញ្ញត្តិ

**មាត្រា ១៤០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តដោយចេតនានូវអំពើណាមួយ ដូចខាងក្រោម ៖

-ចេញបង្កាន់ដៃបញ្ជាក់ការចុះឈ្មោះ ប៉ុន្តែមិនព្រមចុះឈ្មោះប្រជាពលរដ្ឋនោះក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

-ចុះឈ្មោះបោះឆ្នោតដល់ប្រជាពលរដ្ឋ ដែលពុំបំពេញលក្ខខណ្ឌគ្រប់គ្រាន់ អាចបោះឆ្នោតបាន ។

**មាត្រា ១៤១.-**

ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ៥.០០០.០០០(ប្រាំលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលក្លែងបន្លំឯកសារបញ្ជាក់អត្តសញ្ញាណពាក់ព័ន្ធនឹងការបោះឆ្នោត ។

ROYAUME DU CAMBODGE * LE MINISTRE DU PALAIS ROYAL *

**មាត្រា ១៤២.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណា ដែលតាមគ្រប់មធ្យោបាយទុច្ចរិត ៖

-រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោត មិនឲ្យទៅចុះឈ្មោះបោះឆ្នោត ឬរារាំងមិនឲ្យចុះឈ្មោះប្រជាពលរដ្ឋ ដែលមានសិទ្ធិបោះឆ្នោតក្នុងបញ្ជីបោះឆ្នោត និងសៀវភៅបញ្ជីបោះឆ្នោត ។

-បង្កការអុកឡុក ឬរារាំងសកម្មភាពជាប្រក្រតី ក្នុងទីកន្លែងសម្រាប់ការពិនិត្យបញ្ជីឈ្មោះ និងការចុះឈ្មោះបោះឆ្នោត នៅក្នុងអំឡុងពេលនៃការពិនិត្យបញ្ជី និងចុះឈ្មោះបោះឆ្នោត ។

-ឲ្យអ្នកគាំទ្រ ឬអ្នកបោះឆ្នោត ប្រព្រឹត្តអំពើរំលោភបំពាន អំពើគំរាមកំហែង អំពើហិង្សា ទៅលើបេក្ខជន ឬទៅលើគណបក្សនយោបាយដទៃ ។

-រារាំងប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតមិនឲ្យទៅបោះឆ្នោត ។

-រារាំងបេក្ខជន ឬអ្នកគាំទ្រគណបក្សនយោបាយមិនឲ្យឃោសនាបោះឆ្នោត តាមការកំណត់ ។

-ធ្វើឲ្យបាត់ទំនុកចិត្តលើការសម្ងាត់នៃការបោះឆ្នោត ។

-ធ្វើឲ្យមានការភាន់ច្រឡំនាំឲ្យបាត់ទំនុកចិត្តលើការបោះឆ្នោត ។

-បង្កការរំខានមិនឲ្យដំណើរការការបោះឆ្នោតបាន ។

-បង្កការរំខានមិនឲ្យរាប់សន្លឹកឆ្នោតបាន ។

-ធ្វើឲ្យខូចរបៀបរៀបរយក្នុងពេលបោះឆ្នោត ។

-ទិញសន្លឹកឆ្នោតដោយសម្ភារ ឬដោយប្រាក់កាស ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើ ចំពោះជនដែលបានប្រព្រឹត្តអំពើល្មើសដូចមានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

**មាត្រា ១៤៣.-**

ត្រូវលុបបេក្ខភាពឈរឈ្មោះបោះឆ្នោតរបស់គណបក្សនយោបាយ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌដទៃទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តអំពើល្មើសដូចបានចែងក្នុងមាត្រា ១៤២ ខាងលើនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៤៤.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០ (មួយម៉ឺន) រៀល ទៅ ១០០.០០០ (មួយសែន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដោយទុច្ចរិតព្យាយាមចុះឈ្មោះក្នុងបញ្ជីបោះឆ្នោតលើសពីមួយ លើកលែងតែមានការអនុញ្ញាតដោយច្បាប់នេះ ។

**មាត្រា ១៤៥.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះសមាជិកគណៈកម្មការរាជធានី ខេត្ត ឃុំ សង្កាត់រៀបចំការបោះឆ្នោត និងសមាជិកគណៈកម្មការការិយាល័យបោះឆ្នោតដែលបន្លំឯកសារ បន្លំសន្លឹកឆ្នោត ឬប្រើកលល្បិចដើម្បីបន្លំលទ្ធផលនៃការបោះឆ្នោត ។

**មាត្រា ១៤៦.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ គ្រាប់រំសេវគ្រប់ប្រភេទ ឬអាវុធដែលចូលក្នុងដែនអនុវត្តរបស់មាត្រា៤៨៩ (បទផលិត ឬធ្វើជំនួញអាវុធសម្រាប់ប្រហារផ្សេងៗទៀត) នៃក្រមព្រហ្មទណ្ឌ ចូលក្នុងតំបន់ហាមឃាត់ និងក្នុងអំឡុងពេលដូចបានបញ្ញត្តក្នុងមាត្រា ៥២ និងរង្វង់ការពារសន្តិសុខនៃការិយាល័យបោះឆ្នោតដូចបានបញ្ញត្តក្នុងមាត្រា ១១២ នៃច្បាប់នេះ ដោយគ្មានការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ច ឬគ្មានមូលហេតុអនុញ្ញាតដោយច្បាប់ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសនោះជាភ្នាក់ងារ ជាបុគ្គលិក នៃគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ជាភ្នាក់ងារ ជាបុគ្គលិកឬសមាជិកនៃគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ត្រូវលុបឈ្មោះចេញពីការងារនិងមិនឲ្យសាមីខ្លួនចូលបម្រើការងារជាមួយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំចាប់ពីសម័យបោះឆ្នោតនេះទៅ បន្ថែមលើទណ្ឌកម្មដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

**មាត្រា ១៤៧.-**

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវស្នើទៅប្រធានស្ថាប័នរបស់សាមីខ្លួនឲ្យដាក់វិន័យរដ្ឋបាល ចាប់ពីដាក់

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

ឲ្យនៅទំនេរដោយគ្មានបៀវត្សរហូតដល់ការបណ្ដេញចេញពីមុខតំណែងចំពោះមន្ត្រីរាជការ ឬអ្នកទទួលខុសត្រូវណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៨៧ នៃច្បាប់នេះ ។

**មាត្រា ១៤៨.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជាដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោល បំពានលើបញ្ញត្តិនៃមាត្រា ៨៤ នៃច្បាប់នេះ ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គលចំពោះអំពើដដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។

**មាត្រា ១៤៩.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនបរទេសដែលមានវត្តមាននៅក្នុងដែនដីនៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើសកម្មភាពដោយផ្ទាល់ ឬដោយប្រយោលក្នុងចេតនាឃោសនាបោះឆ្នោត ដើម្បីគាំទ្រ ឬប្រឆាំងគណបក្សនយោបាយណាមួយ ឬបេក្ខជនណាម្នាក់ ។

ជនប្រព្រឹត្តអំពើខាងលើ អាចត្រូវបណ្ដេញចេញពីព្រះរាជាណាចក្រកម្ពុជា តាមបែបបទដូចបានចែងក្នុងច្បាប់ស្ដីពីអន្តោប្រវេសន៍ ។

**មាត្រា ១៥០.-**

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលនៅក្នុងពេលបោះឆ្នោតបង្អាប់ បញ្ឆាលួងលោមបោកបញ្ឆោត ឬធ្វើសកម្មភាពតាមគ្រប់មធ្យោបាយទុច្ចរិតផ្សេងទៀតឲ្យអ្នកបោះឆ្នោត បោះឆ្នោតជ្រើសរើសយកគណបក្សនយោបាយផ្ទុយពីឆន្ទៈរបស់ជននោះ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាភ្នាក់ងារ ឬជាបុគ្គលិកគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោត គ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ROYAUME DU CAMBODGE · LE MINISTRE DU PALAIS ROYAL · ព្រះរាជវាំង

ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់)ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

## មាត្រា ១៥១.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២៥.០០០.០០០ (ម្ភៃប្រាំលាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំដោយគណៈ-កម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំគិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដោយចេតនាធ្វើឲ្យខូចខាត បំផ្លិចបំផ្លាញ ឬធ្វើឲ្យទ្រុឌទ្រោមហិបឆ្នោត ឬគ្រឿងសម្គាល់សម្រាប់រក្សាសុវត្ថិភាពហិបឆ្នោត ឬធ្វើឲ្យបាត់ ដកហូត លួច ដណ្តើមកាន់កាប់ ឬបំផ្លិចបំផ្លាញហិបឆ្នោតដែលមានសន្លឹកឆ្នោត ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើសជាភ្នាក់ងារ ជាបុគ្គលិក ឬជាសមាជិកនៃគណៈកម្មាធិការជាតិ ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវលុបឈ្មោះចេញពីការងារ និងមិនឲ្យសាមីខ្លួនចូលបម្រើការងារក្នុងគណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោត ឬគណៈកម្មការរៀបចំការបោះឆ្នោតគ្រប់លំដាប់ថ្នាក់សម្រាប់រយៈពេល ១០ (ដប់) ឆ្នាំ គិតចាប់ពីសម័យបោះឆ្នោតនេះតទៅ ។

ក្នុងករណីជនប្រព្រឹត្តអំពើល្មើស ជាបេក្ខជនឈរឈ្មោះបោះឆ្នោត គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចោលបន្ថែមលើទណ្ឌកម្ម ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

## មាត្រា ១៥២.-

ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល និងត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលតាមគ្រប់មធ្យោបាយ ប្រមាថជាសាធារណៈចំពោះគណបក្សនយោបាយណាមួយ ឬបេក្ខជនឈរឈ្មោះបោះឆ្នោត ឬញុះញង់ឲ្យមានការរើសអើងទៅលើសមាជិកនៃជាតិពន្ធុ ក្រុមជាតិ ពូជសាសន៍ ឬនៃសាសនាណាមួយជាក់លាក់ នៅក្នុងពេលឃោសនាបោះឆ្នោត និងពេលបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ គណៈកម្មាធិការជាតិរៀបចំការបោះ-ឆ្នោតត្រូវលុបឈ្មោះជនប្រព្រឹត្តអំពើល្មើសចេញពីបញ្ជីបោះឆ្នោត សម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ និងត្រូវលុបបេក្ខភាពរបស់សាមីខ្លួនចេញពីបញ្ជីឈរឈ្មោះបោះឆ្នោត ក្នុងករណីដែលជនប្រព្រឹត្តអំពើល្មើសនោះ ជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

**មាត្រា ១៥៣.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ៣០.០០០.០០០ (សាមសិបលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយ ដោយគណៈកម្មា-ធិការជាតិរៀបចំការបោះឆ្នោត ដោយពុំទាន់គិតដល់ទោសព្រហ្មទណ្ឌផ្សេងទៀត ចំពោះគណបក្សនយោបាយដែលបានប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥២ ខាងលើនេះ ។

**មាត្រា ១៥៤.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា ៧៨ ឬកថា-ខណ្ឌទី ២ នៃមាត្រា ៧៩ នៃច្បាប់នេះ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬ/និងត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ២.០០០.០០០ (ពីរលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៥៥.-**

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងមាត្រា៦៨ ក្នុងការហែក្បួនឃោសនាបោះឆ្នោត ឬប្រព្រឹត្តល្មើសនឹងកថា-ខណ្ឌទី ១ នៃមាត្រា ៧២ នៃច្បាប់នេះ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ឬ/និងត្រូវលុបឈ្មោះចេញពីបញ្ជីបោះ-ឆ្នោតសម្រាប់រយៈពេល ០៥ (ប្រាំ) ឆ្នាំ ឬលុបបេក្ខភាពរបស់សាមីខ្លួន ប្រសិនបើជនប្រព្រឹត្តអំពើល្មើសជាបេក្ខជនឈរឈ្មោះបោះឆ្នោត ។

**មាត្រា ១៥៦.-**

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ឬ/និងត្រូវលុបបេក្ខភាពឈរឈ្មោះរបស់គណបក្សនយោបាយដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះគណបក្សនយោបាយដែលប្រព្រឹត្តបទល្មើស ដូចមានចែងក្នុងមាត្រា ១៥៥ ខាងលើនេះ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ១៥៧.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រព្រឹត្តល្មើសនឹងកថាខណ្ឌទី ២ នៃមាត្រា ៧២ នៃច្បាប់នេះ ។

ត្រូវលុបឈ្មោះចេញពីបញ្ជីបោះឆ្នោត ឬលុបបេក្ខភាពរបស់សាមីខ្លួន ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត បន្ថែមលើទណ្ឌកម្មដែលបានចែងក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។

## មាត្រា ១៥៨.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះជនណាដែលប្រើប្រាស់សម្ភារ មធ្យោបាយដឹកជញ្ជូន ដែលជាសម្បត្តិរបស់រដ្ឋ ដើម្បីធ្វើសកម្មភាពឃោសនាឱ្យគណបក្សនយោបាយណាមួយ ឬបេក្ខជនណាមួយ ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ៥.០០០.០០០ (ប្រាំលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ១៥៩.-

ត្រូវផាកពិន័យជាប្រាក់ពី ១០.០០០.០០០ (ដប់លាន) រៀល ទៅ ២០.០០០.០០០ (ម្ភៃលាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ចំពោះអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមក្នុងស្រុក និងអង្គការមិនមែនរដ្ឋាភិបាល ឬសមាគមអន្តរជាតិដែលបំពេញការងារក្នុងព្រះរាជាណាចក្រកម្ពុជា ដែលប្រព្រឹត្តអំពើបំពានមាត្រា ១៣៧ នៃច្បាប់នេះ ។

ការទទួលខុសត្រូវខាងលើ មិនលើកលែងការទទួលខុសត្រូវរបស់រូបវន្តបុគ្គល ចំពោះអំពើដែលខាងលើ ឬបទល្មើសផ្សេងទៀតដែលបានបញ្ញត្តនៅក្នុងក្រមព្រហ្មទណ្ឌនោះឡើយ ។

## មាត្រា ១៦០.-

ត្រូវព្រមានជាលាយលក្ខណ៍អក្សរ ដោយប្រធានគណៈកម្មការការិយាល័យបោះឆ្នោត ចំពោះភ្នាក់ងារគណបក្សនយោបាយ ឬអ្នកសង្កេតការណ៍ដែលផ្តល់ការណែនាំ ឬស្តីបន្ទោសដល់មន្ត្រីបោះ-ឆ្នោត ឬមន្ត្រីរាប់សន្លឹកឆ្នោត ។

ក្នុងករណីដែលនៅតែមិនគោរពតាមការព្រមានខាងលើ ត្រូវផាកពិន័យជាប្រាក់ពី ១.០០០.០០០ (មួយលាន) រៀល ទៅ ១០.០០០.០០០ (ដប់លាន) រៀល ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**មាត្រា ១៦១.-**

តាមសំណើរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរមានសមត្ថកិច្ច អាចសម្រេចដាក់ទណ្ឌកម្មវិន័យ ដោយអនុលោមតាមច្បាប់ និងបទដ្ឋានគតិយុត្តជាធរមាន ចំពោះអ្នករាជការសាធារណៈ ឬ ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត នៅក្នុងក្របខ័ណ្ឌនៃមុខងារ ឬនៅក្នុងពេលបំពេញមុខងារ ដែលបានបំពានបទប្បញ្ញត្តិនៃជំពូកនេះ ។

**មាត្រា ១៦២.-**

អំពើល្មើសដែលប្រព្រឹត្តដោយគណបក្សនយោបាយ គឺជាអំពើល្មើសដែលប្រព្រឹត្តដោយអង្គការ ឬអ្នកតំណាងរបស់ខ្លួន ដើម្បីជាប្រយោជន៍របស់គណបក្សនយោបាយនោះ ។

អង្គការឬអ្នកតំណាងរបស់គណបក្សនយោបាយសំដៅដល់អង្គការឬបុគ្គលដែលមានសិទ្ធិសម្រេចក្នុងនាមគណបក្សនយោបាយ ស្របតាមលក្ខន្តិកៈរបស់គណបក្សនយោបាយនោះ ។

**មាត្រា ១៦៣.-**

បែបបទ និងនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ក្នុងការអនុវត្តបទប្បញ្ញត្តិនៃជំពូកនេះ ត្រូវកំណត់ដោយគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

**មាត្រា ១៦៤.-**

បុគ្គលដែលទទួលរងឥទ្ធិពលដោយផ្ទាល់ ពីសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតដូចមានចែងនៅក្នុងជំពូកនេះ អាចប្តឹងតវ៉ាជាលាយលក្ខណ៍អក្សរទៅក្រុមប្រឹក្សាធម្មនុញ្ញ ក្នុងអំឡុងពេល ៧២ ( ចិតសិបពីរ ) ម៉ោង បន្ទាប់ពីកាលបរិច្ឆេទទទួលបានសេចក្តីសម្រេចនេះ ។

ក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវពិនិត្យ និងសម្រេចលើបណ្តឹងតវ៉ាខាងលើក្នុងអំឡុងពេល ១០ (ដប់) ថ្ងៃ បន្ទាប់ពីកាលបរិច្ឆេទទទួលបានពាក្យបណ្តឹងតវ៉ា ។

សេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញ ជាសេចក្តីសម្រេចស្ថាពរបិទផ្លូវតវ៉ា ។

**មាត្រា ១៦៥.-**

ដំណើរការនីតិវិធី ដើម្បីចេញសេចក្តីសម្រេចរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ឬក្រុមប្រឹក្សាធម្មនុញ្ញ មិនរាំងដំណើរការនីតិវិធីព្រហ្មទណ្ឌឡើយ ក្នុងករណីដែលអំពើបំពានលើបញ្ញត្តិដែលចែងនៅក្នុងជំពូកនេះ ជាបទល្មើសដែលបានបញ្ញត្តក្នុងច្បាប់ព្រហ្មទណ្ឌ ។

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

## មាត្រា ១៦៦.-

បទប្បញ្ញត្តិនៃជំពូកទោល (បទប្បញ្ញត្តិទូទៅ) នៃមាតិកាទី ១ (បទប្បញ្ញត្តិទូទៅ) ជំពូកទោល (ការបង្ខំដល់រូបកាយ) នៃមាតិកាទី ៣ (ការបង្ខំដល់រូបកាយ) នៃគន្ថីទី ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវយកមកអនុវត្ត ក្នុងករណីដែលសេចក្តីសម្រេចអំពីប្រាក់ពិន័យបានចូលជាស្ថាពរ ។

# ជំពូកទី ១១

# អន្តរប្បញ្ញត្តិ

## មាត្រា ១៦៧.-

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតត្រូវរៀបចំបញ្ជីបោះឆ្នោតថ្មី សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់អាណត្តិទី៤ និងធ្វើបច្ចុប្បន្នភាពបញ្ជីបោះឆ្នោត និងចុះឈ្មោះបោះឆ្នោតឆ្នាំ ២០១៧ សម្រាប់ប្រើប្រាស់ក្នុងការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី ៦ ។

ក្នុងការរៀបចំបញ្ជីបោះឆ្នោត ដូចមានចែងក្នុងកថាខណ្ឌទី១ នៃមាត្រានេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវដំណើរការផ្អែកលើគោលការណ៍ដូចមានចែងក្នុងមាត្រា ៣៩ កថាខណ្ឌទី ១ កថាខណ្ឌទី ២ កថាខណ្ឌទី ៣ កថាខណ្ឌទី ៤ និងកថាខណ្ឌទី ៥ នៃមាត្រា ៤៤ មាត្រា ៤៦ មាត្រា ៤៧ មាត្រា ៤៨ មាត្រា ៤៩ មាត្រា ៥០ និងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃចំណុច ក ចំណុច ខ ចំណុច គ និងកថាខណ្ឌទី ១ នៃចំណុច ឃ នៃមាត្រា ៥១ នៃច្បាប់នេះ ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោតអាចប្រើប្រាស់ទិន្នន័យអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ដែលរក្សាទុកដោយក្រសួងមហាផ្ទៃ និងអាចប្រើប្រាស់បញ្ជីបោះឆ្នោតចុងក្រោយសម្រាប់ជាមូលដ្ឋាន ក្នុងការរៀបចំបញ្ជីបោះ ឆ្នោតដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

បែបបទ នីតិវិធី កាលបរិច្ឆេទ និងរយៈពេលនៃការរៀបចំបញ្ជីបោះឆ្នោត ដូចមានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ត្រូវកំណត់ដោយបទបញ្ជា និងនីតិវិធីរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

## មាត្រា ១៦៨.-

បែបបទនៃការបដិសេធការចុះឈ្មោះបោះឆ្នោត ការប្តឹងតវ៉ា និងការដោះស្រាយបណ្តឹងតវ៉ាពាក់ព័ន្ធការចុះឈ្មោះបោះឆ្នោត ការបិទផ្សាយបញ្ជីបោះឆ្នោតដំបូង បែបបទនៃការប្តឹងតវ៉ាអំពីការបាត់បង់ឈ្មោះ ឬប្តឹងជំទាស់អំពីការចុះឈ្មោះ ឬការរក្សាទុកឈ្មោះក្នុងបញ្ជីបោះឆ្នោត និងការបិទផ្សាយបញ្ជីបោះឆ្នោតផ្លូវការ ក្នុងដំណើរការរៀបចំបញ្ជីបោះឆ្នោតថ្មី ដូចមានចែងក្នុងមាត្រា ១៦៧ ត្រូវផ្អែក

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

តាមបទប្បញ្ញត្តិដូចមានចែងក្នុងមាត្រា ៥៣ មាត្រា ៥៤ មាត្រា ៥៥ មាត្រា ៥៦ មាត្រា ៥៧ មាត្រា ៥៨ មាត្រា ៥៩ មាត្រា ៦០ មាត្រា ៦១ មាត្រា ៦២ មាត្រា ៦៣ មាត្រា ៦៤ និងមាត្រា ៦៥ នៃច្បាប់នេះ ។

**មាត្រា ១៦៩.-**

ករណីប្រជាពលរដ្ឋមានឈ្មោះក្នុងបញ្ជីបោះឆ្នោត ស្របតាមបទប្បញ្ញត្តិនៃច្បាប់នេះ ប៉ុន្តែពុំមានអត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរដើម្បីបោះឆ្នោត ប្រជាពលរដ្ឋនោះ អាចប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណដើម្បីបោះឆ្នោត ។

រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ត្រូវចេញសេចក្តីណែនាំរួមអំពីបែបបទ និងនីតិវិធី ដើម្បីឲ្យអាជ្ញាធរឃុំ សង្កាត់ និងគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ផ្តល់ឯកសារបញ្ជាក់អត្តសញ្ញាណ ដូចបានចែងក្នុងកថាខណ្ឌទី ១ នៃមាត្រានេះ ។

## ជំពូកទី ១២
## អវសានប្បញ្ញត្តិ

**មាត្រា ១៧០.-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងច្បាប់នេះ ត្រូវទុកជានិរាករណ៍ និងត្រូវជំនួសដោយច្បាប់នេះ ។

**មាត្រា ១៧១.-**

ច្បាប់នេះ ត្រូវប្រកាសជាការប្រញាប់ ។

ធ្វើនៅ ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៥

**ព្រះហស្តលេខា និងព្រះរាជលញ្ឆករ**

**នរោត្តម សីហមុនី**

ទាអរ.១៥០៣.២៤០

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

លេខ:២៥២ ស.ណ

**សំណៅចែលមានតម្លៃជាការចែកផ្សាយ**

រាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ មីនា ឆ្នាំ២០១៥

**អគ្គលេខាធិការរាជរដ្ឋាភិបាល**

**សយ សុខា**